CEN
CAMBODIA EXPRESS NEWS

**រឿង**

# ផ្ការីកផ្ការោយ

រៀបរៀង

អ្នកស្រី ស៊ុយ ហៀង

រក្សាសិទ្ធិ

ព.ស ២៤៨៥ គ.ស ១៩៥២

## អារម្ភកថា

ស្លាកស្នាមប្រវត្តិសាស្ត្រជាច្រើនបានបង្ហាញឱ្យឃើញថា ជនជាតិខ្មែរជាជនជាតិមួយ មានខឿនអរិយធម៌-វប្បធម៌ដ៏រុងរឿង។ ទោះបីជាមានការរុកទន្ទ្រានពីសត្រូវជិតខាងឬមានចំបាំងរាំងជល់ផ្ទៃក្នុងក៏ដោយ ក៏វិស័យសិល្បៈ-អក្សរសិល្ប៍របស់ខ្លួននៅតែបន្តការវិវត្តន៍ឥតឈប់ឈរ។ ប៉ុន្តែគួរឱ្យអនិច្ចាឆ្នាំ ១៩៧០ រដ្ឋប្រហារមួយបានទម្លាក់ព្រះមហាក្សត្រព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ**

ដែលព្រះអង្គតែងយកព្រះទ័យទុកដាក់លើវិស័យអក្សរជាតិ រហូតប្រជាពលរដ្ឋបានថ្វាយព្រះនាមព្រះអង្គជា ព្រះបិតាអក្សរសាស្ត្រជាតិ។ សង្គ្រាម,របបប្រល័យពូជសាសន៍បានបំផ្លិចបំផ្លាញជាតិគ្រប់វិស័យស្ទើរដល់កម្រិតសូន្យក្នុងនោះមានស្នាដៃអក្សរសិល្ប៍ផងដែរ ។ ក្រោយពីមានការបង្រួបបង្រួមជាតិក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រជនជាតិខ្មែរ បានរួបរួមសាមគ្គីគ្នាជាធ្លុងមួយស្តារនិងកសាងជាតិឡើងវិញ។ ដោយយល់ឃើញពីសារៈសំខាន់នៃវិស័យអក្សរសិល្ប៍ក្នុង




ការលើកស្ទួយវប្បធម៌របស់ខ្លួនបណ្ណាគារ "អង្គរធំ" យើងខ្ញុំក៏បានសំរេចលើកយកស្នាដៃប្រលោមលោកចាស់ៗ របស់អ្នកនិពន្ធដែលធ្លាប់មានឈ្មោះល្បីមកធ្វើការបោះពុម្ពឡើងវិញ ក្នុងគោលបំណងថែរក្សានូវសម្បត្តិរួមរបស់ជាតិដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយបានចេះដឹងគ្រាន់ជាគុណប្រយោជន៏រួមដល់សង្គមជាតិ។

ភ្នំពេញ, ថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០

## ជំពូកទី១

អង្គរវត្ត (ខេត្តសៀមរាប) មានថ្ងៃមួយពេលព្រឹកព្រលឹមមេឃចុះអ័ព្ទសក្បុសដេរដាស បើសិនជាគេផ្ទៀងត្រចៀកស្តាប់ គេនឹងបានឮសូរដល់ចម្រៀងរបស់ស្ត្រីម្នាក់ សំឡេងយ៉ាងក្រលួចបង្ហើរតាមខ្យល់ ឮល្វើយៗមក អាចប្រទាញ

ដល់ទឹកចិត្តអ្នកណាដែលបានស្ដាប់ឱ្យដើររកមើល តើអ្នកម្ចាស់ចម្រៀងស្ថិតនៅត្រង់កន្លែងឯណា។

បើគេមកដល់មុខប្រាសាទបុរាណ គេនឹងបានឃើញរូបនាងកញ្ញាដែលច្រៀងនោះ នាងមានរាងខ្ពស់ស្រឡះ សក់រួញប៉ប្រះស្មា មុខមូលដូចព្រះចន្ទពេញវង់ ភ្នែកភ្លឺខ្មៅស្រិលដូចត្បូងនិល សម្បុរខ្មៅស្រអែម។ នាងឈរត្រដាងក្រមាសមួយបង្អើរតាមវាយោ វាយោក៏ហាក់ដូចជាត្រេកត្រអាលរួមគំនិតជាមួយនឹងនាងកញ្ញានេះដែរ ខំទទះក្រមាសព្ទសូរភឹប១ បីដូចជាសត្វស្លាបទទះចង់ហើរ ឯដើមជ្រៃដែលដុះនៅជិតក៏បក់បោកឮសូរប្រាវ១មានសន្ធឹក ខ្លះដាច់ហើររោយរាយមកគរលើព្រះធរណី។ ចម្រៀងកញ្ញានោះមានពាក្យថា :

| | |
|---|---|
| ឱ ! វាយោបក់មករ៉ូ១ | គួអឺយកាលណានឹងមកដល់ |
| គួរឱ្យខ្ញុំនឹកឡើងពិភាល់ | ក្នុងចិត្តនឹកឆ្ងល់ពន់ប្រមាណ |
| គន់មើលទៅមេឃឃើញងងឹត | ចុះអ័ព្ទផ្សែងព្រិលពេកកន្លង |
| ព្រិច១ ដាសពាសត្រជាក់ផង | គួរឱ្យខ្ញុំផ្សងរកវាសនា ។ |
| ស្រណោះព្រះពាយបក់ក្លិនផ្កា | ដើមជ្រៃសាខាចុះក្បែរស្រះ |
| ដើមស្វាយដុះនៅប្របជិតផ្ទះ | មើលទៅឆ្ងាយណាស់ឃើញលឹម១ |
| យី ឱ ! ប្រាសាទខ្ពស់ត្រដូច | គួរឱ្យចាប់ព្រួចគួចស្នេហា |
| ជុំវិញសុទ្ធសឹងតែទឹកថ្លា | គួរឱ្យអស្ចារ្យស្នាដៃខ្មែរ ។ |
| ស្រណោះប្រាសាទធំល្វឹងល្វើយ | ប្រាសាទអើយអ្នកនៅឯកា |
| ជុំវិញសុទ្ធសឹងព្រៃព្រឹក្សា | សម្ងើមណាស់សាក្នុងស្ថានស្ងាត់ ។ |
| ពេលនេះជាពេលដ៏ត្រជាក់ | គ្មានឃើញមនុស្សម្នាក់ដើរឡើយណា |
| គួរអញទៅបេះប្រឡេះផ្កា | ដុះប្របទឹកថ្លាលាយនឹងស្មៅ ។ |



កញ្ញាកាលបើច្រៀងចប់អស់ចិត្តហើយ នាងក៏ដើរទៅឈោងបេះផ្កា ដែលដុះលាយនឹងស្មៅនៅជិតមាត់ស្រះ លុះបេះបានល្មមហើយនាងដើរតម្រង់ចូលទៅក្នុងថែវប្រាសាទខាងស្តាំដៃ ដើម្បីរកបន់ស្រន់លោកតាដែលមាននាម (ហារីហារា) ដៃប្រាំបី ស្ថិតនៅខាងលិចទ្វារអង្គរវត្ត ប្រាថ្នាសុំឱ្យជួយ ឱ្យបានរួចចាកអំពីសេចក្តីទុក្ខ ដែលដក់ត្រាំនៅក្នុងទ្រូងនាង។

នារីដើរទៅដល់ចំពោះមុខលោកតា នាងលុតជង្គង់យកផ្កាទៅដោតថ្វាយ ហើយលើកដៃប្រណម្យសំពះក្រាបគ្រប់បីដងទើបមានវាចាល្អ១ឡើងថា :

" ឱ ! លោកតា ដែលនៅចាំថែរក្សាអង្គរវត្ត សូមលោកមេត្តាទទួលនូវពាក្យអង្វររបស់នាងខ្ញុំផង ខ្ញុំឈ្មោះនាង **ផាលា** អាយុ ១៦ ឆ្នាំ មានលំនៅក្នុងភូមិមុខនាគ មុខអង្គរវត្តនេះឯង លោកតា ! ខ្ញុំសព្វថ្ងៃក្រខ្លាំងណាស់ ខ្ញុំរស់នៅដោយវេទនា កំព្រាតតឪពុកតាំងពីតូចម្ល៉េះ នៅតែជាមួយនឹងអ្នកម្តាយដែលគាត់ជាមនុស្សជរាពិការខ្វាក់ភ្នែកទាំងសងខាង រាល់ៗថ្ងៃខ្ញុំតែងតែដើររើសអុសសន្សំកំណាត់ឈើងាប់ៗចងជាបាច់១លក់ឱ្យគេគ្រាន់បានប្រាក់បន្តិចបន្តួច យកទៅទិញអង្ករ ត្រីសាច់ចិញ្ចឹមជីវិតអ្នកម្តាយនឹងខ្លួនឯង។ ឱ ! លោកតា ហេតុដូច្នេះហើយបានជាខ្ញុំមករកលោកតា សូមលោកមេត្តាអាសូរដល់រូបខ្ញុំផង កុំអោយជីវិតខ្ញុំរស់នៅក្នុងរណ្តៅអ្នកក្រតទៅអនាគតទៀត ។ លោកតា ! ខ្ញុំដឹងខ្លួនជាក់ដោយខ្ញុំឮសូរគេនិយាយសរសើរជាច្រើនអ្នកថា "រូបខ្ញុំល្អណាស់" សេចក្តីសរសើរនេះហើយអាចដឹកនាំបុរសទុគតិជាច្រើនអ្នកមកដណ្តឹងចង់បានខ្លួនខ្ញុំធ្វើជាភរិយាគេ តែចិត្តគំនិតរបស់ខ្ញុំៗគ្មានសេចក្តីគួចមេត្រី ស្នេះស្នាក់ ចំពោះបុរសដែលទុគតិ ដូចជារូបខ្ញុំនេះទេ ព្រោះខ្ញុំគិតឃើញថា អ្នកទាំងនេះមិនអាចនឹងជួយឃិតយោងខ្លួនខ្ញុំឱ្យរួចអំពីទុក្ខដែលលំបាកវេទនានេះបានឡើយ។ ឱ លោកតា ! ចិត្តគំនិតរបស់ខ្ញុំប្រាថ្នារកចំពោះបុរសឯណាដែលគេមានធនធានទ្រព្យសម្បត្តិវិញ ទើបគេអាចជួយឃិតយោងខ្លួនខ្ញុំឱ្យបានឡើងស្ថានខ្ពង់ខ្ពស់រុងរឿងផុតអំពីសេចក្តីអត់ឃ្លានផុតអំពីសេចក្តីវេទនាបាន ។ ហេតុដូច្នេះ សូមលោកតាមេត្តាបញ្ជូនបុរសឯណាម្នាក់ដែលគេជាអ្នកមានភោគទ្រព្យឱ្យមកដណ្តឹងខ្ញុំធ្វើជាភរិយាគេក្នុងពេលឆាប់ៗនេះទៅ កុំឱ្យខ្ញុំនៅរងទុក្ខវេទនាយូរតទៅទៀត ។ លោកតា ខ្ញុំសូមអរគុណលោកតាទុកជាមុន ខ្ញុំមានសេចក្តីជឿជាក់ថា លោកតា គង់តែមេត្តាបំពេញនូវសេចក្តីបំណងរបស់នារីអ្នកក្រនេះពុំខាន ខ្ញុំមិនភ្លេចគុណលោកតាទេ បើបានដូចសេចក្តីប្រាថ្នា ខ្ញុំនឹងយកដង្វាយដ៏ពិសេសមកថ្វាយលោកតា ពុំហ៊ានខានឡើយ " ។

នាង **ផាលា** បន់ស្រន់រួចហើយក៏ក្រោកឡើងដើរចូលទៅក្នុងព្រៃខាងក្រោយអង្គរទៅ ដើម្បីនាងទៅរករើសមែកឈើណា ដែលងាប់ៗជ្រុះនៅលើស្មៅ ។

បានមួយសន្ទុះធំ ទើបឃើញនាងត្រកងមែកឈើតូចៗដើរចេញមកក្រៅមុខអង្គរវិញ នាងនឹកថា : " អញថ្ងៃនេះម្ដេចក៏រកអុសពុំបានច្រើនសោះបានតែ ៥-៦ ដើម ធ្វើម្ដេចនឹងលក់បានប្រាក់គ្រប់គ្រាន់ទិញម្ហូបម្ហាជូនម្ដាយអញ បើអញ្ចឹងអញត្រូវទៅរកនៅក្បែរអង្គរធំទៀត " ... ។

ដល់ពេលថ្ងៃ នាងកញ្ញាប្រញាប់ប្រញាល់យកកំណាត់ឈើ ដែលបានរកសន្សំបានទាំងប៉ុន្មានទៅលក់ឱ្យគេ បានប្រាក់យកទៅទិញអង្ករបានមួយកំប៉ុង នឹងទិញត្រីតូចតាច ១ចង្កោម យកទៅដណ្ដាំបរិភោគជាមួយម្ដាយ។ ដល់ពេលថ្ងៃរសៀល នាងទទូរក្រមាចេញដើរទៅរករើសអុសទៀត ដើម្បីសន្សំឱ្យបានច្រើនទុករួមដល់ព្រឹកស្អែកទៀត ទាល់តែដល់ពេលព្រលប់ៗទើបបានឃើញនាងត្រឡប់មកផ្ទះវិញ ព្រោះដល់ពេលនាងត្រូវដណ្ដាំបាយ ។



កាលបើបានបរិភោគបាយរួចរាល់ហើយ ពេលព្រលប់ក៏ត្រឡប់ស្លុងមក ដល់នាងកញ្ញាក៏ចូលនិទ្រាជាមួយម្ដាយទៅ ។

លុះដល់ពេលព្រះសុរិយា នាង **ផាលា** ត្រូវដល់ពេលចេញដើររករើសមែកឈើតាមធម្មតាដូចថ្ងៃមុនៗមក តែព្រឹកនេះនាងនឹកភ្នកចង់ចូលទៅលេងក្នុងប្រាសាទអង្គរវត្តសិន នាងនឹកដូច្នោះហើយ នាងដើរតម្រង់ចូលទៅក្នុងប្រាសាទបុរាណទៅ ... ។

ជិតចេញផ្សាយទៀតហើយ !!
រឿង "**នៅក្នុងលោកនេះបើគ្មានបង**" របស់អ្នកនិពន្ធ
**ហាក់ ឆៃហុក** ជាប្រលោមលោកមនោសញ្ចេតនា
ដែលកើតឡើង នាអំឡុងទសវត្សរ៍៦០ ពីបណ្ណាគារ
"**អង្គរធំ**" នេះដដែល ធានាថាល្អពិរោះរណ្ដំ
ក្នុងអារម្មណ៍យុវវ័យគ្រប់ៗរូប !!!

## ជំពូកទី២

ជួនជាពេលហ្នឹង គេឃើញរទេះឡាន (ស៊្វីប) មួយពណ៌លឿង បើកលឿនបង្ហុយដីហុយត្រលោមពីទិសខាងលិចមក មកដល់មុខអង្គររទេះឡាននោះក៏ទប់ហ្វ្រាំងឈប់ង៉ក់ គេឃើញមានបុរសក្មេងៗពីរនាក់ចុះពីឡានមក ម្នាក់មុខមូលទ្រវែង សាច់ខ្មៅ សក់ស្លួត រាងជាមនុស្សសុភាព ។ ម្នាក់ទៀតមុខមូលក្រឡង់ សម្បុរស សក់រួញអង្កាញ់ៗឬកពាជាមនុស្សសង្ហា។

យុវជនទាំងពីរនាក់នេះ លើកប្រដាប់ថតមួយម្នាក់ដាក់ស្ពាយលើស្មា ហើយដើរតម្រង់ចូលទៅអង្គរ ។

បានមួយសន្ទុះក្រោយមក បុរសក្មេងទាំងពីរនាក់នេះក៏ដើរទៅដល់សង្កាត់ប្រាសាទខាងក្នុងបង្អស់ នាំគ្នាគយគន់មើលពីចម្ងាយទៅស្រាប់តែប្រទះឃើញនាង **ផាលា** ដែលនាងកំពុងតែដក់ភ្នែកមើលស្វាឱបកូនឡើងដើមស្វាយ ។

យុវជនដែលមានមុខល្អ កិរិយាជាអ្នកសង្ហា កាលបើក្រឡេកឃើញរូបនាងកញ្ញា ក៏នឹកអរព្រួចគួចស្នេហាភ្លាម ទើបស្រដីប្រាប់ទៅមិត្រថា : **ស៊ីផា** ! **ស៊ីផា** ! ចូរឯងមើលហ្ន៎ ! ស្ត្រីនេះមកពីណាមក មានរូបរាងអីក៏ល្អម្ល៉េះ តើមនុស្សលោកឬក៏ទេវតា បើសិនណាជាមនុស្សលោកទេ គួរតែអញទៅលួងប្រលោមស្នេហា។



**ស៊ីផា** - អើរើយ ! ស្ត្រីរូបរាងល្អមែន តើកូនចៅអ្នកណាបានហ៊ានដើរមកកន្លែងនេះតែម្នាក់ឯង។ កំឡោះ **តារា** ជាមនុស្សធ្លាប់ខិល កាលបើស្តាប់ **ស៊ីផា** ជាមិត្រនិយាយមកផុតសេចក្តីហើយក៏បបួលមិត្រដើរតម្រង់ទៅរកនាង **ផាលា** ភ្លាម។

ឯកញ្ញា **ផាលា** កាលបើបានឮសូរស្បែកជើងមនុស្សដើរព្រឹប១មកជិតខ្លួននាង ក៏ភ្ញាក់ព្រើត ហើយក្រឡេកមើលទៅត្រង់ចំទិសដែលឮសូរនោះ នាងឃើញច្បាស់ជាយុវជនទាំងពីរនាក់ ដើរតម្រង់មករកនាង នាងនឹកក្នុងចិត្តថា : " យី ! មនុស្សប្រុសក្មេង១នេះមកពីណាមកបានជាគេដើរតម្រង់មករកអញ តែអញមានចិត្តគួចមេត្រីទៅលើបុរសម្នាក់ដែលមានរូបល្អនោះ" ....។ នាង **ផាលា** នឹកដូច្នេះហើយ នាងក៏ងើយមើលរុក្ខានានាទៅវិញ នាងធ្វើកិរិយាព្រងើយហាក់ដូចជាមិនដឹងខ្លួន ព្រោះនាងមិនចង់ឱ្យយុវជននេះដឹងចិត្តនាង ។

**តារា** បានដើរជិតនាង **ផាលា** ហើយបញ្ចេញវាចាទៅថា : " ខ្ញុំបាទសូមទោសអ្នកស្រី សូមអ្នកអត់ទោសឱ្យខ្ញុំបាទសូមសួរបន្តិច អ្នកអញ្ជើញមកក្នុងទីនេះតែម្នាក់ឯងទេឬ ? "។

នាង **ផាលា** ឆ្លើយ " ចាំ " រួចនាងឈ្ងោកមុខមើលទៅដី ដោយនាងមានសេចក្តីភ័យនឹងសេចក្តីខ្មាសយ៉ាងពន់ពេក ត្បិតនាងពុំដែលធ្លាប់ចរចាជាមួយនឹងប្រុសកំឡោះឯណាក្នុងទីស្ងាត់សោះឡើយ។

**តារា** -យី ! បើដូច្នេះខ្ញុំបាទមានសេចក្តីស្តាយណាស់ ព្រោះខ្ញុំបាទមានបំណងចង់បានរូបថតកញ្ញាឯណាម្នាក់ដែលមានរូបល្អដូចជារូបអ្នកស្រី ឱ្យបានថតជាប់ជាមួយនឹងប្រាសាទដ៏ឧត្តុង្គឧត្តមនេះ បើសិនណាអ្នកមេត្តាជួយបំពេញបំណងរបស់ខ្ញុំបាទប៉ងមកនេះបានឬទេ ? ខ្ញុំបាទ សូមអរគុណទុកជាមុន ព្រោះខ្ញុំបាទនឹកថា បើទោះតែយ៉ាងណាគង់តែអ្នកអាណិតមេត្តា ឱ្យខ្ញុំបាទថតរូបអ្នកពុំ ខានហើយខ្ញុំបាទសូមសន្យាជូនអ្នកថា ខ្ញុំបាទនឹងលាងពង្រីកឱ្យបានរូបមួយសន្លឹកយ៉ាងធំ យកមកជូនដល់អ្នកស្រី ដើម្បីទុកជាអនុស្សាវរីយ៍របស់ខ្ញុំបាទតទៅអនាគត ។

នាង **ផាលា** កាលបើបានឮសូរសំដីរបស់ **តារា** យ៉ាងពីរោះហុចមកឱ្យចំពោះខ្លួននាង នាងនឹកពេញចិត្តយ៉ាងក្រៃលែង ហើយនាងងើបមុខញញឹមរាងអៀនមើលទៅ **តារា** តែឥតមានចេញវាចាតបទៅវិញសោះឡើយ ។ តែញញឹម

របស់នាង **ផាលា** នេះហើយហាក់ដូចជាសញ្ញាសុខចិត្តព្រមព្រៀងឱ្យ **តារា** ថតរូបខ្លួនចុះ ។

**តារា** ស្គាល់ចិត្តនាងកញ្ញាច្បាស់ ហើយក៏បញ្ចេញទឹកមុខ ញញឹមយ៉ាងស្រស់តបទៅរកនាង **ផាលា** វិញ រួចដើរថយក្រោយលើកប្រដាប់ថតដាក់មើលល្មមតាមពន្លឺបានស្រេចបាច់ហើយក៏ច្របាច់ថតភ្លាមទៅ។ រួចដើរចូលមកជិតនាងវិញ ទើបនិយាយថា : " ថតកន្លែងនេះមើលទៅពុំសូវបានល្អទេអ្នក ព្រោះត្បិតមេឃស្រទុំគ្មានលេចពន្លឺថ្ងៃសោះ បើប្រសិនណាបានទៅថតនៅលើប្រាសាទខ្ពស់នោះវិញប្រហែលបានល្អជាង ព្រោះនៅឯលើមើលទៅឃើញមានពន្លឺច្បាស់បន្តិចបើដូច្នេះ សូមអ្នកអញ្ជើញឡើងទៅលើប្រាសាទថតម្តងទៀតទៅឬ ? " ។

**តារា** និយាយហើយ ក៏ធ្វើជាដើរបន្តិចៗទៅមុខ។ នាង **ផាលា** ដោយត្រូវបំណងខ្លួនក៏ព្រមដើរតាម **តារា** ទៅ ។ ចំណែក **ស៊ីផា** អ្នកគិតក្នុងចិត្តថា : " ឥឡូវនេះ បើអញទៅតាមគេមុខជាគេខ្មាស់អៀន ឬគេទើសទាល់ដោយសាររូបអញ បើដូច្នេះត្រូវតែអញគេចខ្លួនឱ្យបែកពីគេចេញទៅ " ។ អ្នកក៏ធ្វើជាដើរទៅឈ្ងោកមើលក្បាច់ដែលឆ្លាក់ជាប់នឹងជញ្ជាំងថ្មប្រាសាទ មានរូបរឿងរាមកេរ្តិ៍ជាដើម...។

**តារា** និងនាង **ផាលា** ក៏នាំគ្នាឡើងតាមជណ្តើរចោតទៅនៅលើប្រាសាទដ៏ខ្ពស់សន្ធឹមលន្លោច ជាស្ថានស្ងាត់គួរជាទីពេញចិត្តដ៏បរិបូរដល់គំនិតគូនេះ ។ ទើប **តារា** ផ្តើមនិយាយឡើងថា " ខ្ញុំសូមសួរចិត្តអ្នក ហើយនិងសូមជំរាបដោយនៅសេចក្តីត្រង់ តើអូនឯងមានប្តីហើយឬនៅ ? ត្បិតបងមានសេចក្តីស្នេហាលើរូបអូនយ៉ាងពន់ពេកតាំងពីបងចូលមកក្រឡេកមើលទៅឃើញអូនពីចម្ងាយម្ល៉េះ តើអូនមានគំនិតបែបណា សូមអ្នកស្រដីប្រាប់មកបងឱ្យឆាប់មកសោះបងនៅតឹងទ្រូង បងសន្យាក្នុងចិត្តបងថា : បើសិនជាបងពុំបានអ្នកមកធ្វើជាភរិយាទេ បងនឹងសុំលាអ្នកក្ស័យជីពជន្មហើយ ។

**ផាលា** - បង ! ខ្ញុំសូមជំរាបបងដោយនូវសេចក្តីសុចរិត សូមបងចាំស្តាប់ពាក្យខ្ញុំ ខ្ញុំនៅក្រមុំមិនទាន់មានប្តីទេ តែខ្លួនប្អូនជាកូនអ្នកក្រ សព្វថ្ងៃប្អូនរស់នៅដោយវេទនាខ្លាំងណាស់ ព្រោះកំព្រានៅតែជាមួយម្តាយ ដែលគាត់ជាមនុស្សពិការ ងងឹតភ្នែកទាំងសងខាង មើលអ្វីពុំឃើញទេ។ បង ! ខ្ញុំមិនប្រកែកនឹងបំណងរបស់បងទេ តែប្អូនសូមចិត្តបងថា បើសិនអ្នកបានស្នេហាប្អូនហើយ ដល់ទៅពេលក្រោយសូម បងកុំបោះបង់ចោលប្អូនណ៎ា។

ហើយនាងប្រាប់ថា ដល់ពេលព្រលប់ល្ងាចហ្នឹងឱ្យ **តារា** ទៅជួបនៅក្នុងផ្ទះនាង ដែលមានលំនៅក្នុងភូមិ នាគមុខអង្គរវត្តនេះ ។

**តារា** មានសេចក្ដីរីករាយយ៉ាងពន់ពេក និយាយឡើងថា " សូមអូនជឿចិត្តបងចុះ កុំថ្លៃសង្ស័យ ថ្វីបងមិនបោះបង់ចោលអូនទេ បងសូមផ្ញើជីវិតរស់នៅជាមួយនឹងអូនទាល់តែស្លាប់អូនដឹងទេ ? ខ្លួនបងជាកូនចៅអ្នកមានយ៉ាងធំនៅទីក្រុងភ្នំពេញឯណោះ បងនៅកំឡោះឥតទាន់មានប្រពន្ធទេ បងសុំឪពុកម្ដាយបងមកលេងអង្គរ ដើម្បីលំហែចិត្ត។ ដល់ថ្ងៃក្រោយ បងនឹងនាំអូនទៅនៅទីក្រុងភ្នំពេញជាមួយបងពុំខាន អូននៅទីក្រុងភ្នំពេញសប្បាយណាស់ នាងដែលស្គាល់ឬទេ ? " ។

**ផាលា** - បង ! ខ្ញុំពុំដែលស្គាល់ទេទីក្រុងភ្នំពេញនោះ គ្រាន់តែឮសូរគេនិយាយថា នៅទីក្រុងភ្នំពេញ មានមនុស្សអ៊ូអរសប្បាយណាស់ តែខ្ញុំពុំដែលបានទៅម្ដងសោះ ។

ដល់មួយសន្ទុះក្រោយមក នាង **ផាលា** លាសង្សារត្រឡប់ទៅកាន់លំនៅនាងវិញ ។ **តារា** លូកហោប៉ៅ ទាញកាបូបមកបើកហូតក្រដាសប្រាក់ ១០០ រៀល មួយសន្លឹក ហុចទៅឱ្យនាង **ផាលា** ។ នាង **ផាលា** លូកដៃទទួលយកប្រាក់ពី **តារា** ដោយទាំងមានសេចក្ដីរីករាយ ហើយដើរចេញទៅ ។

នាងដើរបណ្ដើរ នាងនឹកបណ្ដើរ : " អញម្ដងនេះមុខតែបានថ្កុំថ្កើង រុងរឿងនឹងគេមិនខានគេចិត្តល្អណាស់ហ្ន៎ អញមិនទាន់ធ្វើជាភរិយាគេផង គេហ៊ានចំណាយប្រាក់គេ ឱ្យមកអញ ទាំងដុលម្ល៉េះទៅហើយចុះទំរាំដល់ថ្ងៃក្រោយទៅទៀត មុខតែគេរិតតែអាណិតអាសូរអញលើសជាងថ្ងៃនេះយ៉ាងណាទៅ។ ឥឡូវប្រាក់នេះតើអញគិតទៅទិញអីខ្លះ ទេ ! ទេ ! ប្រាក់នេះ អញត្រូវយកទៅជូនម្ដាយអញទាំងអស់ ហើយអញនឹងជំរាបរឿងរបស់អញនេះដល់គាត់យ៉ាងត្រង់ ។ ឱ ! ម៉ែអើយ បើម៉ែបានដឹងរឿងកូន ម៉ែសមសប្បាយចិត្តយ៉ាណាទៅ។ ឱ ! លោកតាដ៏ខ្លាំងពូកែអើយ ខ្ញុំសូមអរគុណលោកតាពន់ពេក ខ្ញុំពុំភ្លេចគុណលោកទេព្រោះលោក តាជួយខ្ញុំឱ្យបានឡើងផុតពីរណ្ដៅអ្នកក្រ ខ្ញុំពុំភ្លេចគុណទេបើថ្ងៃទៀតខ្ញុំមុខតែនឹងបានប្រាក់ទៅទិញក្បាលជ្រូក១ យកមកថ្វាយលោកតាពុំខានឡើយ ។

## ជំពូកទី៣

លុះដល់ពេលព្រលប់ ស្រមោលងងឹតលាតត្រដាងដូចជា ស្បៃខ្មៅមួយយ៉ាងធំ គ្របស្លប់ស្លុងមកលើផ្ទៃផែនដី សត្វរៃក៏ស្រែកទ្រហឹងអឹងកង ឯសត្វក្អែកហើររកទ្រនំ សំឡឹងមើលដើមឈើណាធំៗល្មមជ្រកលាក់បំពួនខ្លួន ក្នុងពេលរាត្រីអ្នកស្រុកនាំគ្នាដឹកគោបញ្ចូលក្រោល ។

ស្មើនេះហើយដែល **តារា** ត្រូវដល់ពេលសន្យានឹងសង្សារ អ្នកក៏ស្លៀកពាក់ខោអាវយ៉ាងស្អាត លាបទឹកអប់ក្រអូបឈ្ងុយឈ្ងប់បើករទេះឡាន ស៊ីបសំដៅទៅរកភូមិមុខនាគ ។ លុះដល់ហើយ ក៏ចុះពីលើឡានដើរគយគន់រកលំនៅរបស់នា **ផាលា** ។

មួយសន្ទុះមកនាង **ផាលា** ចេញពីក្នុងខ្ទមមួយដើរតម្រង់ទៅរក **តារា** ។ គូរស្នេហានេះបបួលគ្នាដើរទៅរកទីស្ងាត់ ដើម្បីនឹងនិយាយសំណេះសំណាលសាកសួរគ្នា ។ នាង **ផាលា** បបួល **តារា** ទៅអង្គុយក្រោមដើមអម្ពិលទឹកមួយដើម ដែលដុះនៅដាច់ឆ្ងាយពីភូមិ ។ **តារា** និយាយទៅកាន់នាង **ផាលា** ថា :

- អូន ! ម្ដេចអូនមុខស្រពោន ហើយដូចជាហើមត្របកភ្នែកយ៉ាងដូច្នេះ?



ផាលា - បងអើយខ្ញុំព្រួយចិត្តខ្លាំងណាស់ ព្រោះសេចក្ដីប៉ងប្រាថ្នារបស់យើង ពុំបានសម្រេចដូចចិត្តទេ ដោយខ្ញុំបាននាំរឿងនេះមកជំរាបដល់អ្នកម្ដាយខ្ញុំយ៉ាងត្រង់ ហើយនឹងយកប្រាក់ ១០០ រៀល ដែលបងឱ្យខ្ញុំពីព្រឹកមិញនេះជូនគាត់ គាត់មានប្រសាសន៍ប្រាប់ខ្ញុំថា...( កញ្ញាមានវាចាត្រឹមតែប៉ុណ្ណឹងនាងក៏ យំខ្សឹកខ្សួល រដឹតរដកឡើង ។

**តារា** - អូន ! សូមអ្នកនិយាយរឿងនេះតទៅទៀតឱ្យបងស្ដាប់ផងអូន កុំយំស្រែកអ្វី ។

**ផាលា** - បង ម៉ែខ្ញុំគាត់មានប្រសាសន៍ថា : " កូនអើយ យើងក្រណាស់ នាងកុំលោភចង់បានប្ដីអ្នកមានទ្រព្យសម្បត្តិឡើយ ក្រែងថ្ងៃក្រោយគេបោះបង់ចោលកូននាំឱ្យវេទនា ត្បិតខ្លួនកូនជាស្រី បើមានប្ដីពុំបានប្រកបទេ សមជារងទុក្ខពុំខានឡើយ ម្ដាយចាស់ហើយៗងងឹតទៀតផង មើលអ្វីក៏ពុំឃើញ គិតការអ្វីក៏ពុំលេចដែរ តែម្ដាយពុំចូលចិត្តនឹងគំនិតរបស់ឯងទេកូន ! ចូរនាងប្រយ័ត្ន

ខ្លួនកុំធ្លោយទៅលើបុរសផ្តេសផ្តាសនាំឱ្យខ្មាសដល់អ្នកស្រុក ក្រតែប្រាក់កុំឱ្យក្រចិត្ត ណាកូនណា ! កូនយកប្រាក់នេះប្រគល់ឱ្យគេវិញទៅ ហើយពៅកុំតបមេត្រីទៅលើរូបគេឡើយ ” ។ នាងនិយាយប្រាប់ **តារា** តាមពាក្យម្តាយភ័យអារម្មណ៍ចប់សព្វគ្រប់ហើយ នាងក៏ដកប្រាក់ពីក្នុងហោប៉ៅអាវហុចទៅឱ្យ **តារា** វិញ នាងនឹកពិបាកចិត្តមិនដឹងជាគិតផ្លូវណាឥឡូវ តាមម្តាយអាណិតសង្សារ តាមសង្សារខុសនឹងបណ្តាំម្តាយ ។ តែដល់បន្តិចមកនាងក៏ដកចិត្តកាត់មេត្រីចេញពី **តារា** ព្រោះនាង នឹកស្រឡាញ់ម្តាយនាងជាង ហើយនាងនិយាយប្រាប់ **តារា** ថា : ” ខ្ញុំសូមលាបងហើយកុំបងគិតនឹកអាល័យមករូបខ្ញុំទៀត ។ ប្អូនជាមនុស្សក្រតោកយ៉ាក មិនត្រូវប្រាថ្នាឱ្យហួសប្រមាណទេ ពាក្យម្តាយខ្ញុំទូន្មាននេះ ហាក់ដូចជាមកដាស់សតិវិញ្ញាណខ្ញុំ ” ។ តែពេលនោះ **តារា** ពុំព្រមទទួលយកប្រាក់ពីនាង **ផាលា** វិញឡើយ ហើយ **តារា** និយាយពាក្យយ៉ាងទំអួញអង្វរទៅកាន់នាងថា : ” អូន ! នាង អាណិតតែបងទៅ កែវកុំស្តាប់ពាក្យអ្នកម្តាយថ្វី ព្រោះគាត់ជាមនុស្សចាស់គាត់គិតវែងហួសប្រមាណពេក ហើយគាត់គិតស្មានមកចិត្តបងនេះខុសយ៉ាងស្រឡះ អូន ! បងមិនហ៊ានប្រព្រឹត្តកិរិយាថ្លើមខ្មៅដល់ម្លឹងទេ ! នាងកុំសង្ស័យ បើកែវមិនជឿសោត បងសូមស្បថដល់លោកតាដៃប្រាំបីដែលខ្លាំងពូកែនៅចាំទ្វារអង្គរវត្តនេះជូនដល់អូន ធ្វើជាកសិណសាក្សីចុះ ។ ឱ ! លោកតាដ៏ខ្លាំងពូកែអើយ សូមលោកជួយស្តាប់ពាក្យខ្ញុំសច្ចា បើដល់ទៅថ្ងៃក្រោយខ្ញុំចោលនាង **ផាលា** ខ្ញុំពុំមានចិត្តមេត្រីស្មោះត្រង់ទេ ខ្ញុំធ្វើឱ្យនាងវេទនាដោយសារខ្ញុំនោះ សូមឱ្យលោកតាវាយបំបាក់កខ្ញុំបាទឱ្យស្លាប់ទៅចុះ” ។ ចំណែកនាង **ផាលា** កាលបើបានស្តាប់ពាក្យ **តារា** និយាយមកគួរឱ្យជឿចិត្ត ត្បិតសង្សារយកលោកតាដែលនាងទុកចិត្តមកធ្វើជាប្រធានគួរឱ្យនាងទុកចិត្តបាន នាងក៏បាក់ចិត្តស្លុងទៅលើ **តារា** វិញដោយគិតថា ” សង្សាររបស់អញពិតជាត្រង់ស្មោះចំពោះអញមែន បានជាហ៊ានចេញវាចាស្បថពាក្យធ្ងន់ៗនឹងលោកតាដល់ម្លឹង ” ពេលហ្នឹងនាងក៏ព្រមរួមសេចក្តីស្នេហាដោយស្វាត់កំបាំងជាមួយ **តារា** ទៅ ។



# ជំពូកទី៤

រាល់ថ្ងៃៗឱ្យតែដល់ពេលព្រលប់ **តារា** តែងតែមកលួចជួបនឹងនាង **ផាលា** ។ លុះដល់បានប្រាំថ្ងៃក្រោយមក រឿងដែលស្ងាត់កំបាំងរបស់គូនេះក៏បែកដឹងដល់យាយចាន់ជាមាតានាង **ផាលា**។ យាយចាន់ កាលបើបានដឹងកិរិយារបស់កូនពុំព្រមស្តាប់បង្គាប់គាត់យ៉ាងដូច្នេះហើយ គាត់ក៏មានសេចក្តីទោមនស្សក្នុងចិត្តយ៉ាងខ្លាំងគាត់ពោលតិចៗថា : ឱ កូនរបស់អញមិនគួរចិត្តធំដល់ម្លឹងសោះ ម្តេចមិនស្តាប់ពាក្យទូន្មានរបស់ម្តាយប្រព្រឹត្តចិត្តធំអ្វីម្លេះ រឿងនេះមើលទៅ ពុំបានសេចក្តីសុខតទៅថ្ងៃក្រោយទេ ។ សេចក្តីក្តៅរបស់យាយចាន់ ហាក់ដូចជាភ្លើងចំបើងឆេះបានតែមួយសន្ទុះក៏រលាយសាបសូន្យទៅវិញដោយសេចក្តីអាណិតអាសូរហាក់ដូចជាទឹកត្រជាក់មកស្រោចលប់លើសេចក្តីក្តៅនោះ។ ˝ ឱ ! កូនអើយហេតុតែនៅក្មេងឆោតអីក៏ឆោតម្លេះទេ ! ម្តាយកម្រឃើញកូនអ្នកមានទ្រព្យសម្បត្តិមកស្រឡាញ់កូនអ្នកក្រយ៉ាងដុនដាប ដោយនៅសេចក្តីស្មោះត្រង់ទេ ˝ ។ គាត់ពោលល្ហួៗហើយគាត់ក៏បង្ហូរទឹកភ្នែករហាមមក បានបន្តិចមកគាត់ក៏ប្រវេប្រវាស្ទាបៗដើរចុះពីផ្ទះទៅដី ដើម្បីប្រាថ្នាទៅរកហោធិតា។ គេឮសូរសំឡេងល្វើយៗរបស់យាយចាន់ថា : ˝ កូនអើយ ! អឺយកូន ! **ផាលា** ! អឺ **ផាលា** ! អឺ **ផាលា** ! នៅឯណាម្តាយរកមិនឃើញមកឯណេះមកម្តាយប្រកូតហៅឯណេះ **ផាលា** ! **ផាលា** ! ˝ ។



រាត្រីនោះ ព្រះច័ន្ទពេញវង់បញ្ចាំងពន្លឺរស្មីដេញស្រមោលយាយចាន់ឃើញភាវរកផ្លូវដើររញ៉េរញ៉ៃក្នុងចម្ការដំណាំ ជួនកាលជំពប់ជើងដួលខ្លោក១ បោកក្បាលទៅលើព្រះធរណី ឬក៏ជុំថ្ម ។ ដល់យូរបន្តិចមកឮសំឡេងថ៎ា៖! ថ៎ា៖! របស់នាង **ផាលា** ឆ្លើយចេញពីក្រោមដើមមាក់ក្លឿមក នាងស្រីនេះក៏ស្ទុះយ៉ាងលឿនមកឱបយាយចាន់ដែលឃើញដួលដេកបាត់មាត់ពុំដឹងខ្លួនសោះឡើយ។ នាងលូកដៃស្ទាបមើលដង្ហើមម្ដាយឃើញនៅមានខ្យល់ដើរ ហើយនាងស្រែកហៅថា ... ម៉ែអឺយ ! ម៉ែ ! អឺម៉ែ ! ម៉ែឮសូរសំឡេងកូនហៅឬទេ ? ឈឺង ! ពុំមានឆ្លើយតបតមកវិញសោះ ។ នាង **ផាលា** ភ័យណាស់ ស្រែកហៅ **តារា** ឱ្យមកជួយមើល ម្ដេចបានជាម្ដាយនាងបាត់មាត់យ៉ាងដូច្នេះ ហើយនាងយំរៀបរាប់ថា : " ម៉ែអឺយម៉ែ ! ម៉ែរដើរមករកកូនឬ ? ឱម៉ែ ! កូនបានជាខុសទៅហើយ កូនពុំហ៊ានជំរាបរឿងត្រង់ដល់ម៉ែ សូមម៉ែអត់ទោសឱ្យកូនម្ដង សូមម៉ែឆ្លើយតបមករកកូនវិញមក ស្ងៀមឈឹង ! ។ **តារា** ដើរមកដល់ក៏ស្ទុះទៅជិតនាង ហើយមានវាចាថា " យី ! មិចក៏អញ្ចឹង " ។ នាង **ផាលា** និយាយឡើងថា "សូមបងជួយត្រកងឱបម៉ែយកទៅផ្ទះ " ។ **តារា** ក៏លើកត្រកងយាយចាន់ដើរយ៉ាងលឿនតម្រង់ទៅរកខ្ទម។ នាង **ផាលា** ក៏ដើរតាមក្រោយទៅ។

ដល់មួយសន្ទុះធំមកទើបបានទៅដល់ខ្ទម **តារា** ដាក់យាយចាន់យ៉ាងថ្នមៗទៅលើកន្ទេលកញ្ចូតមួយ ដែលក្រាលនៅលើរនាបផ្ទះ។ ចំណែកនាង **ផាលា** យកចានចាក់ប្រេងដូងមកកោសខ្យល់ឱ្យម្ដាយ ហើយនាងយំស្រែកហៅម្ដាយថា : " ម៉ែ ! ម៉ែ ! ម៉ែ ! មិចអញ្ចឹង ! មិចក៏នៅតែមិនដឹងខ្លួនសោះ ...។

ចំនួនពីរម៉ោងក្រោយមកសំឡេងយំខ្លាំង១របស់នាង **ផាលា** ក៏ឮដល់ផ្ទះជិតខាង គេនាំគ្នារត់មកសួរ។ **ផាលា** ប្រាប់គេថា : " ម្ដាយខ្ញុំស្លាប់ទៅហើយ ប្រហែលជាខ្យល់គរ " នាងលាក់យ៉ាងជិត មិនបង្ហើបប្រាប់រឿងពិតដល់ញាតិឯណាថា : ម្ដាយនាងដើររកហៅនាងដួលដេកនូវកណ្ដាលចម្ការនោះឡើយ ព្រោះនាងនឹកខ្មាស់គេ " ។

ពីរថ្ងៃក្រោយមក ញាតិជិតខាងគេក៏បាននាំគ្នាជួយជ្រោមជ្រែង ដង្ហែខ្មោចយាយចាន់យកទៅបូជានៅវាលស្មៅខាងក្រោយផ្ទះ។

❀ ❀

❀

# ជំពូកទី៥

ចាប់តាំងពីថ្ងៃដែលយាយចាន់អនិច្ចកម្មទៅ **តារា** ក៏មកនៅរួមសុខទុក្ខរាល់ថ្ងៃរាល់យប់ជាមួយនឹងនាង **ផាលា**។

មានថ្ងៃមួយ នៅពេលរសៀលព្រះអាទិត្យបង្អង់នូវកំដៅ គូនេះក៏នាំគ្នាជិះឡានដើរលេងលំហែចិត្ត **តារា** បើកសំដៅទៅរកភ្នំក្រោម ហើយក៏បង្ហួសទៅទន្លេសាប កាលបើទៅដល់ក្រឡេកឃើញជលសាដ៏ធំល្វឹងល្វើយ ព្រះសុរិយាក៏យាងចុះមកទៀបផ្ទាប់ផ្ទៃសាគរហៀបអស្តង្គត គូស្នេហានេះក៏នាំគ្នាទៅអង្គុយលេងលើវាលខ្សាច់តាមមាត់ឆ្នេរទន្លេ។ **តារា** សំឡឹងមើលទៅទឹក មើលព្រះអរុណ ហើយមើលទៅនភាល័យ ទើបចេញវាចាប្រាប់ទៅសង្សារថា : " អូន ! បងមើលទន្លេសាបគួរឱ្យនឹកស្ញើចណាស់ រកកោះរកត្រើយពុំឃើញសោះ អូនដឹងឬទេ ? មើលកប៉ាល់ហោះមួយនោះដែលបើកមកពីភ្នំពេញ កប៉ាល់ហោះនេះមានល្បឿនយ៉ាងម្ល៉េះ គង់តែហោះកាត់វាលជលសានេះអស់ ១ម៉ោងគត់ ទើបបានឆ្លងផុត ។ ( តារា និយាយ ហើយចង្អុលទៅកប៉ាល់ហោះមួយដែលឃើញហោះលឹម១មកនោះ ) ។



**ផាលា** - បងដែលឮគេនិយាយឬទេថា នៅក្នុងបាតទន្លេសាបនេះមានស្នាមព្រះបាទព្រះអង្គមួយជាន់នៅជាប់នឹងថ្ម ទុកកប់ក្នុងបាតទន្លេនេះ ដើម្បីសម្រាប់ឱ្យពួកសត្វទឹកបានថ្វាយបង្គំរំឭកដល់ព្រះអង្គបង ! អញ្ជឹងបានដល់រដូវទឹកស្រកគេថាពួកសត្វទឹកមាន ត្រីជាដើមនាំគ្នាមុជចុះទៅបាតទន្លេ។

**តារា** - រឿងអូននិយាយនេះ ប្រហែលជាពិតមែនហើយព្រោះបងក៏ឮសួរគេនិយាយដូចអញ្ចឹងដែរ អូនដឹងឬទេ ? បងឮគេថានៅឯភ្នំគូលែន ក៏មាន

ព្រះបាទព្រះអង្គជាប់នឹងថ្នូពិតប្រាកដមួយដែរ ព្រះបាទនោះទុកសម្រាប់ឱ្យពួកសត្វគោកគោរពដល់ព្រះអង្គ បងឮគេថាមានសត្វដីវិឧស្សាហ៍នាំគ្នាមកចោមរោមលុតក្រាប ថ្វាយបង្គំចំពោះដល់ព្រះបាទនោះណាស់ ជួនកាលគេឃើញស្នាមជើងនឹងអាចម៍វា ជួនប្រទះឃើញរូបវាហើយគេដឹងថា វាកាច់មែកឈើយកទៅដាក់គ្របលើព្រះបាទ ដើម្បីប្រក់ជាដំបូលឱ្យម្លប់ អើ ! អូនដែលទៅភ្នំគូលែនដែរឬ ទេ ?

**ផាលា** - ខ្ញុំដែលទៅដែរបង ! ទៅបានពីរដង ហើយទៅជាមួយពូ " ឡាច " ដែលគាត់នៅផ្ទះជិតខ្ញុំនោះ គាត់នាំខ្ញុំទៅព្រោះគាត់មានបងប្អូនគាត់នៅលើភ្នំគូលែននោះ បងអើយ ! ភ្នំគូលែនគួរឱ្យសប្បាយណាស់ មានទឹកផុសចេញពីដុំថ្មហូរឮឆរៗ ចាក់ជ្រោះពុំដែលដាច់ នឹងមានព្រៃដុះក្រាសយ៉ាងសំបើម មានដើមម្រេចជាច្រើនដុះលាយឡំជាមួយនឹងព្រៃ។

**តារា** - យី ! មានដើមម្រេចដុះលាយនឹងព្រៃ ម្ដេចក៏គ្មានគេទៅឆ្ការព្រៃវាតដីយក អូន ! ដើមម្រេចនេះជាដើមមានតម្លៃណាស់ អូន ! ប្រហែលនៅជិតភ្នំត្រជាក់បានជាមានដុះឥតមនុស្សដាំ គួរឱ្យស្ដាយណាស់ហ្ន៎ ! ។

**ផាលា** - បង ! មិនអាចនឹងមានអ្នកណាហ៊ានទៅទន្ទ្រានដីឆ្កា ព្រៃរក្សាដើមនោះទេ ព្រោះមិនងាយទេ ពិបាកណាស់ ផ្លូវក៏នៅឆ្ងាយ ព្រៃក៏ដុះក្រាស់។ មួយទៀតប្រយ័ត្នតែខុសមាត់ មុខតែបណ្ដាលគ្រោះថ្នាក់មកដល់ខ្លួនភ្លាម។

**តារា** - ឱ ! គួរឱ្យស្ដាយណាស់អូន បងពុំដែលបានស្គាល់ភ្នំគូលែនសោះ បើដូច្នេះ យើងគិតបបួលគ្នាទៅក្នុងព្រឹកស្អែក ។ បងគិតទៅហៅ **ស៊ីផា** ឱ្យគ្នាទៅផង ។

ពេលនោះព្រះសូរិយាក៏បាត់វង់ស្រមោលងងឹត ក៏សំដែងឫទ្ធិខ្មៅស្លុងៗលេចចេញមក ។ តារា បបួលនាង ផាលា ត្រឡប់ទៅកាន់លំនៅវិញ ។

❀ ❀
❀

**ជំពូកទី៦**

ដល់ពេលភ្លឺព្រិល១ តារា និងនាង ផាលា នាំគ្នាក្រោកចាកអំពីនិទ្រា ម្ចីម្នាដាំបាយវេចកញ្ចប់ ទិញមាន់អាំងបានស្រេចបាច់ហើយក៏នាំគ្នាចេញពីខ្ទម ឡើងទៅជិះរទេះឡាន បរសំដៅមករកហៅ ស៊ីផា ដែលនៅសំណាក់ផ្ទះបងប្អូន ឯសៀមរាប។ លុះបានជួបជុំគ្នាស្រេចបាច់ហើយ តារា ក៏បើកឡានតម្រង់ទៅរកភ្នំគូលែន ។

ដល់បានចំនួនជាង ១ ម៉ោងក្រោយមករទេះឡាននេះបើកទៅដល់ភ្នំគូលែន ។ អ្នកទាំងបីនាក់ក៏នាំគ្នាចុះពីឡានដើរលេងលើកំពូលភ្នំ។ ស៊ីផា ដើររើសចានបុរាណ និងកំទេចអំបែងចានបញ្ចូរង្គ ។ ឯ តារា ដើរគយគន់សំឡឹងមើលព្រៃ មើលដើមម្រេច មើលដើម គូលែនដែលនៅមិនទាន់មានផ្លែ។ ចំណែកនាង ផាលា នាងទៅឈរគន់មើលទឹកដ៏ត្រជាក់ថ្លាយង់ផុះផុល១ចេញពី ថ្ម នាងមានសេចក្ដីរីករាយអន្លង់អន្លោចយ៉ាងក្រៃលែង។ វាយោក៏បក់មក រំភើយ១ ហាក់ដូចជាមកបបោសអង្អែលមុខនាងឱ្យញញឹមប្រឹមប្រិយ។



ដល់ពេល[illegible]ទៅជ្រកម្លប់ ក្រោមដើមឈើ ហើយក៏ស្រាយបាយពីកញ្ចប់ស្លឹកឈូក និងយកមាន់អាំងមក បរិភោគ និយាយគ្នាលេងសើចក្អាកក្អាយយ៉ាងសប្បាយ ដល់បរិភោគរួចហើយ នាំគ្នានិទ្រាសម្រាកកាយក្រោមដើមរុក្ខានោះទៅដល់ល្ងាច ទើបបបួលគ្នាត្រឡប់ទៅកាន់លំនៅខ្លួនវិញ ។

ក្នុងពេលរាត្រីហ្នឹង តារា នឹកឃើញពាក្យសន្យាជាមួយនឹងមាតា បិតាខ្លួនថា ខ្លួនមកនេះតែត្រឹម ១៥ថ្ងៃទេ ខ្លួននឹងត្រូវត្រឡប់ទៅផ្ទះវិញ ឥឡូវនេះមកជាប់ចិត្តជាមួយនឹងនាង ផាលា អស់រយៈពេល ២០ថ្ងៃទៅហើយ ឱ ! ឪពុកម្ដាយអញអើយសមជាព្រួយគិតមកអញមិនខាន ។ អ្នកព្រួយអារម្មណ៍ខ្លាចមាតា បិតាអ្នកកើតទុក្ខចាំទន្ទឹងមើលផ្លូវអ្នក ព្រោះហួសសន្យា ៥ថ្ងៃមកហើយ អ្នកក៏បន្លឺសំឡេងប្រាប់ទៅនាង ផាលា ថា :

" អូន ! លាក់បាំងអ្វី បងនិយាយប្រាប់នាងឱ្យត្រង់ទៅចុះ បងព្រួយចិត្តខ្លាំងណាស់ត្បិតកាលបងចេញពីផ្ទះមកនេះបងប្រាប់ឪពុកម្ដាយបងថា មកលេង

តែ ១៥ ថ្ងៃទេ ឥឡូវនេះគិតទៅ មកនៅដល់ ២០ ថ្ងៃទៅហើយ ត្រូវហួសកំណត់ ៥ថ្ងៃហើយ សមគាត់ទន្ទឹងចាំមើលផ្លូវបងយ៉ាងណាទៅ ហេតុដូច្នេះបងសូមលាអូនត្រឡប់ទៅភ្នំពេញវិញក្នុងព្រឹកស្អែកនេះហើយ បងសូមសន្យានឹងអូនថា : បងទៅតែ ១០ថ្ងៃទេ បងនឹងត្រឡប់មកយកអូនទៅនៅជាមួយគ្នា ឯទីក្រុងភ្នំពេញ។ អូន! ផ្ទះបងធំណាស់សង់អំពីឥដ្ឋប្រក់ក្បឿងនៅក្បែរមាត់ទន្លេ ឪពុកបងឈ្មោះ **ឪម្តាយបងឈ្មោះ សាយ** គាត់ធ្វើជំនួញ ។ សព្វថ្ងៃគាត់ស្រឡាញ់ថ្នាក់ថ្នមបងខ្លាំងណាស់ពុំដែលហ៊ានឱ្យបងកើតទុក្ខព្រួយអ្វីឡើយ ទោះតែបងចង់បានវត្ថុអ្វីក៏ដោយ គាត់តែងតែរកឱ្យបំពេញចិត្តបងជានិច្ច ព្រោះត្បិតគាត់ឥតមានកូនណាទៀតក្រៅពីរូបបងទេ។ អូន បងគិតត្រឡប់ទៅជំរាបរឿងយើងដែលស្រឡាញ់គ្នានេះដល់គាត់ ដើម្បីឱ្យគាត់បានដឹងមុនផង សឹមបងត្រឡប់មកវិញមកយកអូនទៅ សូមពៅនៅឱ្យសុខកុំកើតទុក ណា៎។

នាង **ផាលា** កាលបើឮពាក្យសង្សារនិយាយប្រាប់មក គិតបែកពីខ្លួនទៅលំនៅរបស់គេវិញហើយ នាងនឹកព្រួយធ្លាក់ទឹកមុខស្រពោនហើយ និយាយទៅវិញថា : សូមបងកុំអាលអញ្ជើញទៅ តែបងទៅប្អូនមុខតែកើតទុក្ខពុំខានឡើយ បើបានបងនៅគ្រាន់បានពីរអ្នក បងនាំប្អូនដើរលេងឯណេះឯណោះ ប្អូនក៏បានរសាយទុក្ខខ្លះមិនសូវនឹកដល់អ្នកម្តាយពេក ដោយសារបានបងជួយរំលត់ទុក្ខ បើបងទៅហើយ ប្អូនមុខតែកំរើកទុក្ខព្រួយដែលព្រាត់ម្តាយស្លាប់ទៅថ្មីៗនេះពុំខានឡើយ។

**តារា** - អូនកុំឃាត់បងឱ្យនៅក្នុងខ្ទមនេះយូរថ្ងៃទៀត បងមិនដឹងនៅទេ ឥឡូវនេះកាន់តែចង្អៀតតប់ប្រមល់ក្នុងចិត្ត ហើយចំណែកអូនក៏អញ្ចឹងដែរ ត្រូវតែផ្លាស់កន្លែងនេះចោលទៅ ទៅនៅជាមួយបង បងទៅតែត្រឹម ១០ថ្ងៃគត់ បងនឹងត្រឡប់មកយកអូនទៅនៅជាមួយ អូនទ្រាំនៅម្នាក់ឯងតែ ១០ថ្ងៃទេតើ ម្តេចក៏តូញត្អែរម៉្លេះ អូន ! នៅទីក្រុងភ្នំពេញសប្បាយណាស់ ប្រាកដជាបងមកទទួលយកអូនទៅនៅជាមួយបងពុំខាន ។

នាង **ផាលា** បានស្តាប់សំដីសង្សារនាង គេប្រកែករឹងប៉ឹងពុំព្រមនៅហើយគេអង្វរថា គេទៅតែ ១០ថ្ងៃទេ គេនឹងមកយកនាងទៅនៅជាមួយនឹងគេឱ្យនាងទ្រាំនៅម្នាក់ឯងសិនទៅ គេទៅមិនយូរទេ។ នាងគិតវែងឆ្ងាយសព្វគ្រប់ទៅ " បើអញឃាត់គេ ក៏គេពុំព្រមនៅតទៅទៀតដែរ បើដូច្នេះត្រូវតែអញបណ្តោយឱ្យគេទៅចុះ មួយទៀតពាក្យដែលគេសន្យានឹងអញនេះ សមជាស្មោះត្រង់ពិត " ហើយនាងឆ្លើយប្រាប់ទៅ **តារា** វិញថា :

សូមបងអញ្ជើញទៅចុះ តែបងកុំភ្លេចរូបខ្ញុំណា៎ ក្នុងរវាង ១០ថ្ងៃ តោងបងមកយកខ្ញុំទៅផងកុំឱ្យខ្ញុំនៅម្នាក់ឯងយូរថ្ងៃពេកណាបងណា៎!។

**តារា** - នៃអូន ! ស្រីកុំភ័យ បងមិនចេះនិយាយក្រឡាស់ដូចកូនក្មេងនោះទេ បងមិនប្រាថ្នាមកបោកនាងឱ្យកើតទុក្ខដោយសាររូបបងទេ ចូរអូនចាំឱ្យជាក់ អូនរាប់ចាប់តាំងពីថ្ងៃស្អែកនេះទៅឱ្យតែបានគ្រប់ ១០ថ្ងៃ ប្រហែលនៅពេលថ្ងៃរសៀលម៉ោង ៣ បងនឹងមកដល់ហើយ អូនចាំមើលផ្លូវបងចុះ"។

ជិតចេញផ្សាយទៀតហើយ !!

រឿង "**នៅក្នុងលោកនេះបើគ្មានបង**" របស់អ្នកនិពន្ធ

**ហាក់ នៃហុក** ជាប្រលោមលោកមនោសញ្ចេតនា

ដែលកើតឡើង នាអំឡុងទសវត្ស៦០ ពីបណ្ណាគារ

"**អង្គរធំ**" នេះដដែល ធានាថាល្អពិរោះរណ្ដំ

ក្នុងអារម្មណ៍យុវវ័យគ្រប់ៗរូប !!!

## ជំពូកទី៧

លុះកាលបើស្រមោលងងឹតសន្សឹមៗថយទៅ ព្រះអរុណក៏ផុសដួងចេញធ្លោឡើងពីទិសបស្ចិម គងនៅទៀបដងព្រៃព្រឹក្សាដាលកំទេចមាសដ៏ក្រហមឆ្អិនឆ្អៅ ច្រាលដេរដាសជុំវិញវង់ មាន់រងាវ "កុកកែលកឹត" រង្វើល១ដល់ បានចំនួន២០នាទី មកឮកាន់តែរន្ថើនឡើង១ " កុកកែលកឹត កុកកែលកឹត១" សំរែករបស់សត្វលួត "គូត១ គូត១" យ៉ាងញាប់ ហាក់ដូចជាមិនចេះហត់ ឬមិន ចេះអស់ចិត្តសោះឡើយ។

នាង **ផាលា** ប្រញាប់ប្រញាល់ក្រោកពីនិទ្រារៀបចំបត់សំលៀកបំពាក់ប្រដាប់ប្រដារបស់ស្វាមីទុកឱ្យស្រេចដល់ដួងជីវិត នាងភ្ញាក់នាងក៏ជញ្ជូនយកទៅដាក់ក្នុងរទេះឡាន។

មួយស្របក់មក រទេះឡានស៊ីប៉េក៏បើកចេញផុតពីភូមិមុខនាគទៅ... នៅសល់តែដីហុយសំពោង មានក្មេង១ដឹកគោដើរកាត់ដីហុយត្រលោមនោះ នាង ផាលា បាត់១ឃើញ...។ នាង ក៏ដើរចូលទៅក្នុងខ្ទមនាងវិញ នាងទៅសំឡឹងធាតុ

ម្ដាយនាង ដែលដាក់ក្នុងថូកែវកៀនជញ្ជាំង នាងពោលខ្សិបៗថា : "ឱ ! ម៉ែអើយ នៅឃើញតែឆ្អឹងស ប្រផេះៗ ម៉ែមិនគួរស្លាប់ទៅចោលកូនសោះ ឱ្យកូននៅតែម្នាក់ឯង ប៉ុន្មានថ្ងៃមុនបានបង តារា គេនៅជាមួយ ឥឡូវនេះ គេទៅចោលបាត់ .... ស្ងាត់ណាស់ម៉ែអើយ កូនព្រួសូរតែសម្លេងរបស់សត្វ តែបង តារា គេថាគេទៅតែ ១០ ថ្ងៃទេ គេត្រឡប់មកយកកូនទៅនៅឯភ្នំពេញជាមួយនឹងគេហើយម៉ែ ! បើកូនមានសំណាងបែបយ៉ាងនេះ កូនស្ដាយខ្លាំងណាស់ ស្ដាយដោយសារ ម៉ែស្លាប់ ម៉ែពុំបាននៅរស់ពិសាបុណ្យរបស់កូន " (នាងពោលល្ហូៗ មុខស្រម៉ូតដល់ចប់ចុងពាក្យ នាងប្រែទឹកមុខញញឹមញញែមទៅវិញ ដោយនាងនឹកថា អនាគតរបស់នាងមុខតែថ្កុំថ្កើងរុងរឿងពុំខាន)។

កន្លងផុតពីថ្ងៃចាស់ផ្លាស់ថ្ងៃថ្មីរៀងៗមក នាង ផាលា រាប់គ្រប់ ១០ថ្ងៃ ហើយនាងគិតថា : " បង តារា ត្រូវគ្រប់ថ្ងៃសន្យាមកដល់ក្នុងពេលល្ងាចនេះហើយ "។ នាងមានសេចក្ដីត្រេកអរយ៉ាងក្រៃលែង នាងបន់សុំឱ្យល្ងាចឆាប់ៗទៅ ដើម្បីនឹងបានឃើញមុខបន្ទូលចិត្តរបស់នាង នាងដើរទៅជំរាបធាតុម្ដាយនាងម្ដងទៀតថា : " ម៉ែល្ងាចថ្ងៃនេះ បងតារា គេមកដល់ហើយ បើគេមកក្នុងល្ងាចនេះ ដល់ព្រឹកស្អែកគេនឹងនាំកូនចេញចាកពីខ្ទមនេះ ទៅនៅឯភ្នំពេញហើយម៉ែ ម៉ែកូនព្រួយចិត្តត្បិតកូនពុំឃើញរូបម៉ែ ម៉ែមិនគួរអនិច្ចកម្មចោលកូនឱ្យនៅកំព្រាសោះ បើម៉ែនៅគ្រាន់បានពីរនាក់ម្ដាយនិងកូន ទៅភ្នំពេញទៅទាំងអស់គ្នា ឥឡូវម៉ែស្លាប់សូន្យទៅហើយ កូនក៏នៅតែក្បាលមួយម៉ង់ៗម្នាក់ឯង"។

ថ្ងៃហ្នឹងចាប់តាំងពីព្រលឹមទល់ព្រលប់ នាង ផាលា ចាំមើលផ្លូវ តារា ពុំឃើញមកដល់សោះ ទឹកមុខនាង ផាលា ដែលកំពុងតែរីករាយក៏ប្រែទៅជាស្រពោនក្រៀមក្រំទៅវិញ ។ តែនាងពុំទាន់កើតទុក្ខស្មោះអស់ពីពោះនោះទេ ព្រោះនាងនៅនឹករំពឹងថា: ចាំមើលថ្ងៃស្អែក ឬខានស្អែកទៀត ព្រោះក្រែងសង្សារនាងមានធុរៈយ៉ាងដូចម្ដេចបានជាពុំឃើញមក"។

និយាយពី តារា វិញ កាលបើមកដល់ទីក្រុងភ្នំពេញហើយ ក៏លែងគិតនឹកនាដល់នាង ផាលា ឡើយ តារា ភ្លេចនឹកអាសូរដល់ស្ត្រីទុគ៌ត តារា ភ្លេចនឹកដល់ពាក្យដែលខ្លួនបានសន្យាឱ្យនាងចាំមើលផ្លូវថា ខ្លួននឹងត្រូវត្រឡប់ទៅយកនាងមកនៅជាមួយ សេចក្ដីកំណត់ទុកក្នុងដួងចិត្តតារាទាំងអម្បាលម៉ាន ពេលនេះក៏ដូចជា រលាយរលត់សាបសូន្យអស់។ មួយថ្ងៃៗ តារា គិតតែស្លៀក ពាក់ហឺហាបើកឡានសង្ហាដល់ពួកស្រីៗ។ ប្រុសស្អាតនេះឧស្សាហ៍ចូលទៅរកផ្ទះ ហាងស៊ីផឹកណាដែលធំៗ មានក្មេង មានពួកស្រីខូចៗច្រៀងរាំ នោះ តារា ក៏ចូល ទៅច្របូលច្របល់ ស៊ីផឹក ប្រកៀកប្រកិតជាមួយនឹងស្រីខូចទាំងនោះ តារា តែងតែចូលចិត្តប្រព្រឹត្តចិត្តខិលខូចយ៉ាងដូច្នេះរាល់ៗថ្ងៃ។

មានថ្ងៃមួយ ពេលល្ងាចត្រជាក់ **តារា** បញ្ចិះឡានស្រីម្នាក់បើកសំដៅទៅរកផ្ទះ **ស៊ីផា** នៅផ្សារស៊ីលីប ។

**ស៊ីផា** ឃើញមិត្រមកដល់ក៏ចេញមកទទួល ដោយនូវសេចក្ដីរីករាយ ហើយនិយាយខ្សឹបៗទៅកាន់មិត្រថា :

" **តារា** ឯងមិនអាណិត នាង **ផាលា** ទេឬ ? បានជាដើរសង្ហាទៅសឡាញ់ពួកស្រីខូចយ៉ាងដូច្នេះ ឯងប្រុងចោលស្រីកំព្រានោះហើយ ? ឯងមិននឹកអាសូរដល់គ្នាដែលនៅវេទនាចាំមើលផ្លូវឯង ណោះទេ ?។ នាង **ផាលា** នាងពិតមែនតែកូនអ្នកក្រ តែនាងមានកិរិយា ឫកពាសុភាពរាបសា អញសំឡឹងមើលទៅមិនដែលឃើញទាស់ភ្នែក រូបរាងគ្នាក៏ល្អគួរសមដែរ **តារា**ឯងមើលអញចិត្តស្មោះមិនដូចឯងទេ ! អញតែបានស្រឡាញ់ស្រីឯណា ឱ្យតែមានចិត្តស្មោះត្រង់ ស៊ូប្ដូរមកលើរូបអញ អញមិនដែលចោលគេទេ ទោះស្ដ្រីនោះរូបរាងពុំល្អ កូនអ្នកក្រ ដុនដាបយ៉ាងណាក៏ដោយ អញមិនបញ្ឆោតឱ្យគេបង់ខ្លួនបង់ឈ្មោះ ទូលទុក្ខវេទនាដោយសារលើរូបអញទេ ។ សេចក្ដីស្នេហានេះធំបំផុតក្នុងលោក ឯងដឹងឬទេ ? មានមនុស្សខ្លះ ហ៊ានប្រហារជីវិតខ្លួនដល់ទៅក្ស័យក៏មានដែរ ព្រោះតែងប់មុខលើផ្លូវតណ្ហានេះ។ ឯងចាំមើលប្រពន្ធអញ អញហៅឱ្យចេញមកឱ្យឯងមើលក្នុងឥឡូវ "។ **ស៊ីផា** និយាយហើយក៏ស្រែកហៅភិរយាខ្លួនថា : " **សាវី** ! **អីសាវី** ! ចេញមកក្រៅឯនេះបន្ដិច " មិនយូរប៉ុន្មានស្ដ្រីម្នាក់ឫកពាយ៉ាងសុភាពរាងជាមនុស្សស្លូតបូតចេញមកដល់ភ្លាម ។ **ស៊ីផា** បង្គាប់ភរិយារបស់ខ្លួនឱ្យសំពះសួរ **តារា** ប្រាប់ថាត្រូវជាសំឡាញ់។ ហើយ **ស៊ីផា** ឱននិយាយខ្សឹបដាក់ត្រចៀក **តារា** តិចៗថា : ឱ នេះហើយ ជាកូនអ្នកក្រម្នាក់ រូបរាងគ្នាក៏ពុំសូវស្អាតដែរ ឯងមើលចុះ តែអញអាណិតឰិតគេមានសេចក្ដីមេត្រីស្មោះត្រង់ស៊ូប្ដូខ្លួនគ្នាមកលើរូបអញ ។

ពេលនោះ **តារា** ពុំមានចេញវាចាមួយមាត់តបសោះឡើយ គ្រាន់តែធ្វើមុខញញឹមៗ ។ ចំនួន ១០នាទី ក្រោយមកក៏លាមិត្រ ហើយត្រឡប់នាំស្រីខ្លួនត្រឡប់ទៅកាន់ទីលំនៅរបស់ខ្លួនវិញទៅ។

ចំណែក **ស៊ីផា** ឈរមើលហើយគ្រវីក្បាលដកដង្ហើមធំ រួចអ្នកនិយាយរឿងរ៉ាវពី **តារា** និងនាង **ផាលា** តាំងពីដើមរហូតដល់ចុងប្រាប់ទៅភរិយាអ្នក ហើយអ្នកនិយាយតទៅទៀតថា : ខ្លួនអ្នកបានជួយនិយាយរំឭកដាស់តឿន **តារា** ជាច្រើនដងដែរ តែឥតអំពើទេ ជួនកាល **តារា** គេបែរទៅជាខឹងនឹងអ្នកវិញ ស្រែកគំហកឱ្យអ្នកថា " កុំចេះដឹងនិយាយអី " ចិត្ត **តារា** រឹងណាស់ ឯឪពុកម្ដាយរបស់តារានេះស្លូតបំផុត ស្រឡាញ់កូនណាស់បណ្ដោយតាមតែចិត្តកូនទេ។

នាង **សាវី** កាលបើឮស្វាមីនិយាយសាស័ព្ទប្រាប់រឿងរបស់**តារា** និងនាង **ផាលា** នាងមានសេចក្ដីតក់ស្លុតរន្ធត់ក្នុងចិត្តហាក់ដូចជាឃើញរូបស្ត្រីម្នាក់ដែលកំពុងតែវេទនា សោយសោកាមកនៅចំពោះមុខ៧នាង។ នាងនិយាយទៅកាន់ប្ដីនាងថា : ឱ អ្នកបង ! ខ្ញុំមានសេចក្ដីអំណរគុណនឹងអ្នកបងឥតឧបមា ប្អូនស្ញើចចិត្តដ៏សប្បុរសរបស់អ្នកបងដែលមិនធ្វើឱ្យប្អូនកើតទុក្ខដូចជារូបគេ ប្អូនសូមជ្រកក្រោមម្លប់ឈើដ៏ត្រជាក់នេះទាល់តែស្លាប់ បងអាណិតកុំបែកចិត្តចោលប្អូនឡើយណា៎ ។

ពេលនោះវាយោក៏បក់មករវិច១ ចោលក្លិនផ្កាចម្ប៉ា ផ្កាម្លិះ ផ្កាកូលាបដែលដុះចេញផ្កាសក្បុសក្បាយនៅមុខផ្ទះគូនេះ ក្រអូបឈ្ងុយឈ្ងប់មក ហាក់ដូចជាមកអង្អែលដួងចិត្តដល់ស្វាមី ភរិយានេះឱ្យរីងរឹតតែស្និទ្ធស្នាល អាណិតអាសូរគ្នាលើសជាងពីដើមទៅទៀត **ស៊ីផា** លូកដៃអង្អែលក្បាលនាង**សាវី**។


ជិតចេញផ្សាយទៀតហើយ !!

រឿង "**នៅក្នុងលោកនេះបើគ្មានបង**" របស់អ្នកនិពន្ធ

**ហាក់ ឆៃហុក** ជាប្រលោមលោកមនោសញ្ចេតនា

ដែលកើតឡើង នាអំឡុងទសវត្ស៦០ ពីបណ្ដាគារ

"**អន្ទរធំ**" នេះដដែល ធានាថាល្អពិរោះរណ្ដំ

ក្នុងអារម្មណ៍យុវវ័យគ្រប់ៗរូប !!!


## ជំពូកទី៨

ចំណែកនាង **ផាលា** ទន្ទឹងចាំមើលផ្លូវ**តារា**ពីមួយថ្ងៃទៅមួយថ្ងៃ រហូតទៅដល់ ៩០ថ្ងៃ ត្រូវបីខែគត់ នាងពុំបានយល់មុខដួងជីវិតនាងសោះឡើយ ដូច្នេះ

ហើយ នាងក៏ត្រូវរងទុក្ខយ៉ាងទម្ងន់អស្ចារ្យនេះមកឱបក្នុងទ្រូង ហាក់ដូច **តារា** បាញ់ព្រួញមួយមកត្រូវចំបេះដូងនាង នាងតែងតែឈឺចុកអួលផ្សារាល់ៗថ្ងៃ បាយក៏បរិភោគលែងឆ្ងាញ់ ដំណេកពុំដែលលក់ស្កប់ស្កល់ ទឹកភ្នែកចេះតែហូរមកគ្មានរំហែ នាងឧស្សាហ៍ទៅសំបូងសម្រូងរំឭកបន់ស្រន់លោកតានឹងធាតុម្ដាយនាង សុំឱ្យជួយនាងផង តែខំនាងមុខតែក្ស័យជីវិត។

ថ្ងៃមួយ នាងអង្គុយជញ្ជឹងគិតថា : " សង្សាររបស់អញម្ដេចពុំឃើញមកសោះ តើគេមានគំនិតគីតបែបណាបានជាបាត់រូបសូន្យ ធ្វើឱ្យអញកើតទុក្ខវេទនារង់ចាំមើលផ្លូវគេរាល់ៗថ្ងៃពុំដែលបានល្ហែទុក្ខពីក្នុងទ្រូងសោះ ឱ! គូជីវិតប្អូនអើយម្ដេចឡើយភ្លេចប្អូនយ៉ាងដូច្នេះ បីខែហើយបងពុំឃើញមករកប្អូន ឱ ! កម្មអើយមកផ្ដល់ហើយឬ ?។ ហើយនាងរឭកនឹករឿងរ៉ាវរបស់នាងតាំងពីដើមដំបូង នឹកតាំងពីនាងទៅច្រៀង រួចនាងទៅបន់លោកតាប្រាថ្នារកប្ដីអ្នកមាន នាងចូលទៅក្នុងអង្គរ កំពុងតែគន់មើលសត្វស្វាមើលរុក្ខានានា ស្រាប់តែឃើញ **តារា** និង **ស៊ីផា** មកដល់។ **តារា** លួងលោមស្នេហានាង ហើយឱ្យប្រាក់នាង ១០០ រៀល នាងក៏ព្រមសញ្ញាឱ្យ **តារា** មកជួបគ្នានៅក្នុងផ្ទះនាង រួចនាងយកប្រាក់ ១០០ រៀល និង ដំណឹងនេះទៅជំរាបត្រង់ដល់មាតា នឹងមាតានាងបានហាមឃាត់នាងឱ្យយកប្រាក់ទៅឱ្យ **តារា**វិញ ដល់ពេលល្ងាចនាងបានទៅជួប**តារា** រួចបបួលគ្នាទៅអង្គុយក្រោមដើមអម្ពិល នាងចរចារឿងរ៉ាវប្រាប់ពីមាតានាង ដែលហាមនាងមិនឱ្យស្នេហាបុរសអ្នកមានទ្រព្យសម្បត្តិពេលនោះ នាងក៏យកប្រាក់ឱ្យ**តារា** វិញ នាងប្រព្រឹត្តតាមបណ្ដាំម្ដាយនាង តែ**តារា** ពុំព្រមទទួលយកប្រាក់វិញសោះ **តារា** ចេះតែលួងលោមអង្វរនាង ហ៊ានស្បថពាក្យជ្រៅៗដល់លោកអ្នក តាឱ្យនាងទុកចិត្ត។

កាលហ្នឹងហើយ ហេតុតែកម្មអ្វីមកប្រទាញចិត្តនាងឱ្យជឿស្លុងតាមតារាទៅ ។ រួចនាងនឹកឃើញដល់ម្ដាយនាងដែលស៊ូដើររកនាងទាល់តែដួលបាត់មាត់ដល់ស្លាប់ នាងបញ្ជាក់ក្នុងចិត្តនាងថា : "ម្ដាយអញស្លាប់ ដោយសារតែគិតរូបអញ នាងនឹកឈឺចិត្តដោយខ្លួនប្រព្រឹត្តគំនិតអាក្រក់ អាសូរដល់ម្ដាយពន់ពេកមិនដឹងជាមានបាបអីមកប្រទាញចិត្តឱ្យទន់តាម **តារា** ។ " អញម្ដងនេះសមខ្មាសអ្នកស្រុកពុំខាន ឱ ! ទេវតាអើយជួយខ្ញុំផង តើប៉ុន្មានថ្ងៃទៀតទើបបានបង តារាមក " រួចនាងនឹកតទៅទៀត នឹកដល់ **តារា** នាំបញ្ឆិះឡានដើរលេងទៅទន្លេសាបទៅភ្នំគូលែន យប់ដែលមកពីភ្នំគូលែនវិញនេះឯង តារា និយាយលួងលោមឱ្យនាងនៅម្នាក់ឯងសិនចុះចាំគេទៅប្រាប់ឳពុកម្ដាយគេតែ ១០ថ្ងៃទេ គេនឹងត្រឡប់មកវិញ មកយកអញទៅនៅជាមួយគេឯភ្នំពេញ ។ ពេលនោះនាងខំអង្វរ តារាកុំអាលទៅ ព្រោះនាងមានទុក្ខនៅថ្មីៗម្ដាយនាងស្លាប់អាណិតនៅជួយកំដរ ដើម្បី

បណ្តោះទុកនាងប៉ុន្មានថ្ងៃទៀតសិន។ **តារា** ប្រកែកយ៉ាងរឹងប៉ឹងថាៈ " គេទ្រាំនៅតទៅទៀតពុំបានទេត្បិតគេខ្លាចឪពុកម្តាយគេចាំមើលផ្លូវ គេមកជាប់នៅនឹងនាងហួសពាក្យសន្យាម្តាយឪពុកគេ៥ថ្ងៃទៅហើយ គេមិនអាចនៅក្នុងខ្ទមនាងតទៅទៀតបានឡើយ សេចក្តីធុញទ្រាន់របស់គេមកជ្រៀតក្នុងចិត្តគេហើយ សូមចិត្តនាងកុំឱ្យឃាត់។ នាងនឹកដល់សំដីរបស់ **តារា** ត្រង់កន្លែងនេះហើយដែលនាំឱ្យនាងភ្ញាក់ខ្លួនព្រើត ដោយនាងគិតឃើញថា :

បង តារា ប្រហែលជាគេជិនឆ្អន់នឹងរូបអញដោយសារតែខ្លួនអញក្រមើលទៅបានជាគេចេញសំដីថា គេនៅក្នុងខ្ទមរបស់អញលែងបាន ពាក្យនេះហើយដែលគួរឱ្យអញគិតពិចារណា អាណិតរូបពន់ពេកខ្លួនអើយ ! ខ្លួនជាកូនអ្នកក្រ មិនគួរទៅលោភ ហ៊ានមេត្រីលើគេ ព្រោះគេជាកូនអ្នកមានទ្រព្យសម្បត្តិនេះហើយមកពីគំនិត គិតខុសគិត ខាតថាចំណេញ មិនស្តាប់ទូន្មានរបស់ម្តាយ បានជាមកថ្ងៃនេះខ្លួនចំបែងក្នុងទ្រូងដល់ម្ល៉េះ ប្រហែលជាគេបោះបង់ចោលអញហើយ .....។

បួនថ្ងៃហ្នឹង ត្រូវជាថ្ងៃចូលឆ្នាំខ្មែរ នាង **ផាលា** នាងតែងតែដើរចេញមកនៅដើមផ្លូវមុខអង្គរវត្តដើម្បីខំគយគន់រកមើលក្រែងឃើញថ្លើមប្រមាត់របស់នាងមក ចាប់តាំងពីព្រលឹមទល់ព្រលប់ តែឥតប្រយោជន៍ទេ គ្មានឃើញសោះ៥ថ្ងៃមកហើយ ឃើញតែមនុស្សដទៃទៀតមាន ជាតិបារាំង អង់គ្លេស អាមេរិកាំង សៀម លាវ ចិន យួន ខ្មែរ ។ល។... គេនាំគ្នាប្រជ្រៀតដើរហូរហែសើចសប្បាយទ្រហឹងអឺងកង នឹងមានរទេះឡានតូចធំ ម៉ូតូស៊ីក៏ រទេះកង់បន្តោងសន្តោងបើកបរច្រវាត់តាមផ្លូវ។ ភ្លេងសៀម ភ្លេងទ្រត ភ្លេងអាយ៉ៃរបស់ពួកអ្នកស្រុក គេលើកគ្នាទៅលេងថ្វាយព្រះអង្គក្នុងអង្គរព្ទសូររងំគគ្រំៗ គេលេងសើចសប្បាយយ៉ាងក្អាកក្អាយ។

លុះដល់រាត្រីកាន់តែយន់ទៅនាង **ផាលា** ទូលទុក្ខកាន់តែធ្ងន់ឡើងៗនាងនឹកថា : "មានតែខ្លួនអញម្នាក់ទេ ! ដែលត្រូវទទួលទុក្ខម្នោម្នេញមហាស្ចារ្យ ឱបក្នុងឱរ៉ាបែបយ៉ាងនេះ។ ឱ ! រទេះឡានដួងជីវិតអញអើយ ម្តេចក៏ពុំឃើញមកឃើញតែរទេះឡានរបស់គេដទៃៗ ឱបងអើយ ម្តេចភ្លេចពាក្យសច្ចារបស់បងអ្នកយកកំបិតយ៉ាងស្រួចរបស់អ្នកមកចុចចំបំពង់ករបស់ប្អូន អ្នកម្តេចមិនអាសូរដល់ទ្រូងខ្ញុំផង អ្នកភ្លេចបណ្តាំរបស់ប្អូនអស់ហើយឬ ? ឬអ្នកមានកិច្ចការធុរៈបែបយ៉ាងណា បានជាបងមិនឃើញមក អ្នកធ្វើព្រងើយកន្តើយពុំគិតដល់ប្អូនឡើយខ្លួនប្អូនសព្វថ្ងៃដូចជាមនុស្សមានតែរូបឥតវិញ្ញាណទេបង!។

នាងកើតទុក្ខក្តៅក្រហល់ក្រហាយក្នុងប្រាណដូច្នេះហើយ នាងមិនអាចនឹងនៅក្នុងខ្ទមសុខឡើយ ទើបនាងចេញពីខ្ទមដើរសំដៅទៅរកវាលស្មៅដែលនៅ

ខាងក្រោយផ្ទះ។ នាងងើយមើលទៅមេឃ ឃើញពណ៌ខៀវខ្មៅ តែមានពន្លឺភ្លឺ១ ដុំធំ គឺដួងព្រះចន្ទរះពេញវង់ ព្រមទាំងឃើញផ្កាយលេចព្រោងព្រាតចោលពន្លឺរស្មីភ្លឺព្រិចៗមកតែពេលនោះឃើញមានពពកអណ្តែតទាំងអន្លាយៗមកជិតវង់ព្រះចន្ទ្រា នាងតឹងទ្រូងណាស់ក៏ស្រែកច្រៀងប្រាថ្នាបន្ទប់នូវសេចក្តីទុក្ខខ្លះ មានព្ពាក្យល្វើយៗថា :



ឱ ! គូវាសនាវាសនាអើយ    កាលណាឡើយនឹងបានជួបមុខ
ឱ្យខ្ញុំបាត់អំពីក្តីទុក្ខ    តែខំខ្ញុំមុខទុក្ខដល់ក្ស័យ
តែខំខ្ញុំមុខទុក្ខដល់ក្ស័យ ។    ឱ ! ព្រះចន្ទ្រាចន្ទ្រាអើយ
អ្នកម្តេចភ្លឺម្ល៉េះគួរសង្ស័យ    ត្រចះត្រចង់លើនភាល័យ
សំបើមពេកក្រៃឥតពណ៌នា    សំបើមពេកក្រៃឥតពណ៌នា ។
នែ ! ពពកអើយពពក    កុំរសាត់មកបិទព្រះចន្ទ
ខ្ញុំមានសេចក្តីគួចប្រកាន់    អាណិតព្រះចន្ទនៅកន្តើយ
អាណិតព្រះចន្ទនៅកន្តើយ ។    អូ ! អូ ! ពពកមកកាន់តែជិត
ដុំផ្ទាំងធំពិភពលោកអើយ    រសាត់មកគ្របវង់ចន្ទហើយ
ចន្ទអើយគេចទៅកុំតោះតើយ    ចន្ទអើយគេចទៅកុំតោះតើយ ។
អូ ! អូ ! ពពកមិនខ្ចីអាណិត    បិទវង់ចន្ទពិតបាត់ទៅហើយ
ខ្លួនខ្ញុំមិនងាយរួចទុក្ខឡើយ    កាលណានឹងបានស្បើយដូចចន្ទ្រា
កាលណានឹងបានស្បើយដូចចន្ទ្រា។

នាង **ផាលា** នាងច្រៀងចប់ហើយនាងក៏ប្រះខ្លួននិទ្រាលើស្មៅនោះលក់ទៅ។ ដល់កណ្តាលអាធ្រាត្រយប់ជ្រៅ នាងបានសុបិន្តឃើញថា : " ដូចជាខ្លួននាងធ្វើដំណើរចាកចេញអំពីស្រុកទៅរកដួងជីវិតរបស់នាង ដែលនៅឯទីក្រុងភ្នំពេញ ។ មិនយូរប៉ុន្មាននាងក៏បានទៅដល់ទីក្រុងដ៏ធំអស្ចារ្យដែលនាងពុំធ្លាប់

ស្គាល់សោះ តែនាងពុំមានការតក់ស្លុតស្មារតីគិតភ័យអ្វីឡើយ នាងដើរតាមក្បែរមាត់ទន្លេរកគយគន់លំនៅដួងជីវិតរបស់នាង។ ស្រាប់តែបន្តិចមកឮសូរសំរែកមាត់មនុស្សប្រុសស្រែកហៅនាង នាងងាកមុខមើលទៅឃើញច្បាស់ជាដួងជីវិតរបស់នាង គេញញឹមសើចមករកនាង ហើយហៅនាងឱ្យចូលទៅក្នុងផ្ទះគេ ។ តែផ្ទះ នោះឃើញដូចជាខ្ទមទេ នាងអត់ឆ្ងល់ពុំបាននាងក៏សួរទៅ គូនាងវិញថា : "បង ! ក្រែងបងមានប្រសាសន៍ប្រាប់ខ្ញុំថា ផ្ទះបងសង់អំពីឥដ្ឋប្រក់ក្បឿងឬ? ឥឡូវម្តេចក៏ឃើញផ្ទះស្លឹកឈើ រយីករយាកយ៉ាងដូច្នេះទៅវិញ ? " ។ **តារា** ឮសូរនាងសួរដូច្នោះក៏កើតសេចក្តីខឹងនឹងនាងជាខ្លាំង ស្ទុះទៅយកភ្លើងចន្លុះមកដុត



ផ្ទះនោះឱ្យ... របស់នាងនោះដោះសំលៀកបំពាក់ដែលមានពណ៌សស្អាតរបស់ខ្លួនក្រវាត់ចោលចេញទៅ ទៅរើសយកក្រណាត់ក្រមាមួយពណ៌លឿងមករុំខ្លួនទៅវិញ។

ពេលនោះ ទឹកសន្សើមនឹងវាយោដ៏ត្រជាក់ល្ហឹមល្ហៃក៏កាន់តែធ្លាក់បង្អើរមកលើផ្ទៃផែនដី ធាតុដ៏ត្រជាក់យ៉ាងនេះហាក់បីដូចជាមកដាស់នាង **ផាលា** ដែលកំពុងយល់សប្តិអរផងភ័យផងនោះឱ្យភ្ញាក់ឡើង។

នាងស្ត្រីនេះក៏ភ្ញាក់ស្មារតីដឹងខ្លួនឡើងទើបនាងនឹកថា : " យី ! អញអម្បាញ់មិញនេះយល់សប្តិទេតើ ! តែយល់សប្តិនេះ មុនដំបូងអញដូចជាអរយ៉ាងខ្លាំង អរដោយបានជួបគូរបស់អញ គេហៅរាប់អានអញដល់ ទៅក្រោយក៏ត្រឡប់ទៅជាភ័យវិញ ភ័យដោយឃើញគូរបស់អញគេដុតផ្ទះគេ ហើយឃើញគេដោះខោអាវរបស់គេបោះចោល រួចទៅរើសយកក្រណាត់ក្រមាពណ៌លឿងទុំមករុំខ្លួនគេវិញ។ អញឆ្ងល់ណាស់ ! បើយល់សប្តិយ៉ាងនេះមិនដឹងជាគេកាត់ថាដូចម្តេចទៅអេះ ?។ តែអញមិនភ្លេចទេថា ព្រឹកស្អែកអញគិតប្រថុយទៅភ្នំពេញដើម្បីទៅរកមើលបង **តារា** តើហេតុយ៉ាងណាបានជាគេមិនឃើញមក ឬមួយគេ

លែងគិតគួរដល់រូបអញហើយ បើគេពិតជាបោះបង់អញមែន អញក៏ត្រូវតែឱ្យដឹង សោះនៅទន្ទឹងចាំមើលផ្លូវគេតទៅទៀត។ តែបើតាមអញយល់សប្តិឃើញដូចជា គេហៅរករាក់ទាក់នឹងអញណាស់ ឱអញគិតធ្វើម្តេចទៅ ! បើអញគ្មានប្រាក់នឹង ធ្វើសោហុយទៅសោះ មែនហើយគិតទៅនិយាយនឹងពូឡាចឱ្យគាត់ដើរ រកខ្ចី ប្រាក់គេឱ្យចុះប្រហែលជាចំនួន ២០០ រៀល ទើបបានគ្រប់គ្រាន់សោហ៊ុយ " ។ នាងគិតដូច្នោះហើយ នាងក៏ក្រោកពីវាលស្មៅនោះដើរទៅរកនិទ្រាក្នុងខ្ទមនាង វិញ ។

❀ ❀
❀

| |
|---|
| ជិតចេញផ្សាយទៀតហើយ !! |
| រឿង "**នៅក្នុងលោកនេះបើគ្មានបង**" របស់អ្នកនិពន្ធ |
| **ហាក់ នៃហុក** ជាប្រលោមលោកមនោសញ្ចេតនា |
| ដែលកើតឡើង នាអំឡុងទសវត្ស៦០ ពីបណ្ណាគារ |
| "**អង្គរធំ**" នេះដដែល ធានាថាល្អពិរោះរណ្តំ |
| ក្នុងអារម្មណ៍យុវវ័យគ្រប់ៗរូប !!! |

## ជំពូកទី៩

លុះដល់ព្រលឹមភ្លឺស្រាងៗនាងក្រោកពីនិទ្រាដើរសំដៅទៅរក ផ្ទះពូ ឡាច ដើម្បីទៅពឹងគាត់ឱ្យខ្ចីប្រាក់គេឱ្យ។ ជួនជាព្រឹកហ្នឹង ពូឡាចរៀបទៅបើក ប្រាក់ថ្លៃឈ្នួលដែលគាត់បានធ្វើការឱ្យគេមកនោះ។ មួយសន្ទុះគាត់បានប្រាក់ ២០០ រៀលមកហុចឱ្យនាង **ផាលា** ។ នាង **ផាលា** កាលបើបានទទួលប្រាក់ពី ដៃ **ពូឡាច** ហើយនាងក៏ប្រញាប់ប្រញាល់ចេញដំណើរមកកាន់សៀមរាប រួចជិះ ឡានបន្តទៅភ្នំពេញ។

ចំនួន ៧ ម៉ោងក្រោយមក ប្រហែលជាម៉ោង ៣ថ្ងៃរសៀល នាងផាលា បានមកដល់ភ្នំពេញ ។ នាងសួរគេរកផ្លូវមាត់ទន្លេនៅឯណា គេចង្អុលប្រាប់ ។ មួយសន្ទុះមកនាងបានទៅដល់មាត់ទន្លេ នារីខំគយគន់រកមើលផ្ទះថ្មដែលសង់ហួរ ហែបែរមុខឆ្ពោះទៅមាត់ទន្លេទាំងនោះ ។ បន្តិចមកនាងបានឃើញផ្ទះមួយមាន រទេះឡានស៊ីបពណ៌លឿងចតនៅចិញ្ចើមថ្នល់មុខផ្ទះនោះ នាងអរព្រួច ហើយ គិតថាៈ "រទេះឡាននេះពិតជារបស់បង តារា ឱ ! ប្រហែលជាផ្ទះនេះហើយ ផ្ទះ

របស់គូអញ្ច កញ្ញាគិតដូច្នេះហើយ នាងក៏ឈប់ឈរវេរានៅមុខផ្ទះនោះ តែនាងពុំអាចនឹងហ៊ានចូលទៅក្នុងផ្ទះនោះទេ ! នាងគ្រាន់តែឈរ ឬអង្គុយនៅខាងក្រៅចាំគន់រកមើលគូរបស់នាង។

ប្រហែលជាកន្លះម៉ោងក្រោយមកស្រាប់តែឃើញ **តារា** បណ្ដើរស្រីម្នាក់ដើរចេញពីផ្ទះតម្រង់ទៅរកជិះឡានដែលចតនៅមុខផ្ទះនោះ។

ឱ គួរឱ្យអាសូរ

នាង **ផាលា** កាលបើឃើញសង្សារនាងគេប្រព្រឹត្តគំនិតយ៉ាងដូច្នេះហើយ នាងក៏ភ្ញាក់សតិព្រើត នឹកក្ដៅក្ដុកចុកក្នុងទ្រូង នាងនឹកតូចចិត្តនឹងវាសនារបស់នាងឥតម្ល៉េះទេ នាងត្រជាក់អស់ខ្លួនប្រាណ តែហេតុអំណាចសេចក្ដីអាល័យ និងសេចក្ដីមិនទាន់អស់ចិត្តរបស់នាងក៏អាចប្រទាញចិត្ត នឹងប្រទាញជំហានរបស់នាងឱ្យឈានដើរទៅរកហៅ តារា។

" បង ! អឺបង ! បង ប្អូនមករកបង" (សម្លេងយ៉ាងស្រួយ ហើយញ័រៗ) របស់នាងក៏កំរើកក្នុងចិត្តឡើងថា : " អញមិនត្រូវយកកេរ្តិ៍មកចោលនៅដោយស្រុកគេទៀតទេ ! បើទោះតែយ៉ាងណាចាំទៅដល់ស្រុកកំណើតរបស់អញវិញ ស្អុយឈ្មោះតែក្នុងស្រុកបានហើយ កុំដើរមកឱ្យស្អុយដល់ស្រុករបស់គេទៀត " ។ នាងគិតដូច្នោះហើយ នាងក៏ក្រោកដើរទៅមាត់ទន្លេ ទាំងមានដំណើរធឹងធោង នាងបន់ព្រះសុំឱ្យឆាប់ភ្លឺឡើង ដើម្បីនាងនឹងត្រឡប់ទៅស្រុកនាងវិញ។ រាត្រីហ្នឹងនាងទៅអង្គុយសញ្ជប់សញ្ជឹងក្រោមក្រំលើតាំងស៊ីម៉ង់ក្នុងសួនច្បារមុខមន្ទីរពេទ្យធំទាល់តែភ្លឺ ។

លុះដល់ភ្លឺព្រលឹមៗ ព្រះអាទិត្យមិនទាន់បញ្ចាំងកំដៅរស្មីនៅឡើយ នាង **ផាលា** ក៏ទៅរកចំណតរទេះឡានដែលនៅខាងលិចផ្សារធំថ្មី ដើម្បីត្រឡប់ទៅរកស្រុកកំណើតរបស់នាងវិញ។

ដល់ពេលថ្ងៃរសៀល នាងកំព្រានេះក៏បានមកដល់ខ្ទមលំនៅខ្លួនវិញ។ នាងទៅឈ្ងោកមើលធាតុរបស់ម្ដាយនាង ហើយនាងពោលខ្សឹបៗឡើងថា : " ម៉ែ ! គំនិតដែលកូនគិតមកនោះពិតជាខុសហើយ "។ រួចនាងដើរចេញពីខ្ទមទៅទៅរកផ្ទះ **ពូឡាច** ដល់មុខផ្ទះ នាងស្រែកប្រាប់ទៅ **ពូឡាច** ថា :

" មា ! កាលណាបើឥតពីខ្ញុំទៅ មាយកផ្ទះនិងដីភូមិរបស់ខ្ញុំនេះទៅចុះណា៎។ "

**ពូឡាច** និយាយតបមកនាងវិញថា : " អូ ! ក្មួយមកពីភ្នំពេញវិញហើយ ! មិចទៅនាង គិតទៅនៅឯភ្នំពេញវិញនៅថ្ងៃណា ? ( គាត់គិតស្មានក្នុងចិត្តគាត់ថាប្រហែលជានាង **ផាលា** ត្រឡប់មកប្រាប់គាត់ឱ្យយកផ្ទះដីភូមិនាង នាងនឹងគិតទៅនៅឯភ្នំពេញវិញ )។

ចំណែកនាង **ផាលា** នាងឥតនិយាយតប **ពូឡាច** វិញឡើយ ហើយនាងប្រញាប់ប្រញាល់ដើរចេញទៅ ...។ គេឃើញ នាងដើរយ៉ាងលឿនដំរង់ទៅរកភ្នំបាក់ខែង ។

✿ ✿
✿

ជិតចេញផ្សាយទៀតហើយ !!
រឿង "**នៅក្នុងលោកនេះបើគ្មានបង**" របស់អ្នកនិពន្ធ
**ហាក់ ឆៃហុក** ជាប្រលោមលោកមនោសញ្ចេតនា
ដែលកើតឡើង នាអំឡុងទសវត្ស៦០ ពីបណ្ណាគារ
"**អក្ខរធំ**" នេះដដែល ធានាថាល្អពិរោះរណ្តំ
ក្នុងអារម្មណ៍យុវវ័យគ្រប់ៗរូប !!!

និយាយពី **តារា** វិញ ផុតយប់ដែលជួបនឹងនាង **ផាលា** ចូលមកកាន់យប់ថ្មីទៀត ទើបបាននឹកឃើញទោសកំហុសរបស់ខ្លួន ដែលបានប្រព្រឹត្តជ្រុលហួសទៅលើនាង **ផាលា** ឥតមានប្រណីបន្តិចបន្តួចសោះ ហើយនឹងនឹកឃើញដល់ពាក្យ **ស៊ីផា** ដែលបានពន្យល់ដាស់តឿនខ្លួនរឿយៗមក។

បុរសគិតថា : " ឱ ខ្លួនអញចំជាគិតខុសទៅហើយ មិនគួរគប្បីអ្វីអញប្រព្រឹត្តចិត្តអាក្រក់ដល់ម្ល៉េះសោះ អញបោះបង់ចោលនាង **ផាលា** មិនមានគិតចិត្តអាណិតអាសូរដល់គ្នាសោះឡើយ ដល់គេខំត្រដេត្រដរស្វែងមករកអញទៀត អញនៅតែគិតមិនឃើញ ហើយអញបញ្ចេញសំដីធំៗទៅរកនាង។ ឱ អូន ! ម្ល៉េះសមអូនកើតទុក្ខយ៉ាងណាទៅ យប់នោះមិនដឹងជាទៅគេងនៅឯណា បើនៅក្នុងភ្នំពេញនេះ នាងពុំមានស្គាល់ដល់អ្នកឯណាម្នាក់សោះ យប់នោះសមជាអូនវេទនាពុំខានឡើយ បងគិតខុសទៅហើយ បងមិនគួរភ្លេចពាក្យសច្ចារបស់បងសោះ មិនគួរភ្លេចសំដីដ៏ពីរោះរបស់អូនទេ អូននិយាយមកបងម្តងណាក៏ដោយតែងតែពីរោះជាដរាប គួរតែឱ្យបងនឹកអាឡោះអាល័យ មិនគួរភ្លេចកើតសោះកម្មអ្វីពេលអូនមករកបង នាំឱ្យបងវង្វេងសេចក្តីមេត្តាទៅជាធ្វើតោះតើយហើយប្រើសំដីអាក្រក់ទៅរកអូន ឥឡូវនេះមើលទៅប្រហែលជាអូនត្រឡប់ទៅស្រុករបស់នាងវិញហើយ។ ឱ ! លោកអ្នកតាហារីហារាអើយ ខ្ញុំបាទបានជាប្រព្រឹត្តគំនិតជ្រុលខុសទៅហើយ សូមលោកតាកុំយកទោសខ្ញុំឡើយ ដល់ព្រឹកស្អែកនេះ

ខ្ញុំនឹងធ្វើដំណើរទៅកាន់សៀមរាប ដើម្បីទៅរកនាង ផាលា វិញ ហើយលោកតា ! ចាប់តាំងពីត្រឹមពេលនេះតទៅខ្ញុំផ្លាស់គំនិតចោលហើយ ខ្ញុំលែងដើរខិលខូចដូចពីដើមទៀតហើយ។ ផាលា ! ម្តងនេះបងសូមសច្ចាធិដ្ឋាន កប់ទុកក្នុងដួងចិត្តរបស់បងថា បងនឹងទទួលយកនាងធ្វើជាភរិយាបងពេញច្បាប់ យើងនឹងនៅរួមសុខទុក្ខជាមួយគ្នារហូតទាល់ស្លាប់ ទោសកំហុសរបស់បងទាំងអម្បាលម៉ាន សូមអូនលើកចោលចេញទៅ ពីថ្ងៃនេះតទៅបងលែងឱ្យអូនព្រួយចិត្តដោយសារបងទៀតហើយ " ។

**តារា** គិតដូច្នោះហើយយប់ហ្នឹងអ្នកនិទ្រាពុំលក់ឡើយ អ្នកប្រុងក្នុងចិត្តថា ព្រឹកឡើងអ្នកទៅតាមរកនាង **ផាលា**។

លុះដល់ព្រឹកឡើងកាលណា នាលិកាក្នុងផ្ទះ**តារា** វាយភ្លេងរួចវាយសូរម៉ឹង៧៦ដង សញ្ញាឱ្យដឹងថា ម៉ោង៦ ហើយ។ **តារា** ប្រញាប់ប្រញាល់ចេញរទេះឡានបើកសំដៅទៅរកខេត្តសៀមរាប ៨ម៉ោងក្រោយមក **តារា** បានមកដល់ខេត្តសៀមរាប អ្នកបើកបន្តទៅកាន់ភូមិមុខនាគ ដែលជាស្រុកកំសត់កម្រ អ្នកធ្លាប់មកជ្រកនៅ។ លុះដល់ភូមិមុខនាគហើយ **តារា** បញ្ឈប់រទេះឡានចុះដើរតម្រង់ឆ្ពោះទៅរកខ្ទមនាង **ផាលា**។



តែពេលនោះអស្ចារ្យណាស់ ស្រាប់តែឃើញមនុស្សដែលនៅក្នុងស្រុកគេនាំគ្នាផ្អើលឈូឆរទាំងចាស់ទាំងក្មេងមកចោមរោមមើល **តារា** ដូចជាប្រាថ្នាចង់ស្គាល់មុខបុរសនេះ តែអ្នកទាំងនោះសឹងមានមុខស្រពោនក្រៀមក្រំ ហើយនិយាយខ្សឹបខ្សៀវអំពីរឿងរ៉ាវរបស់ **តារា** ប្រាប់ដល់គ្នីគ្នា ... ។

ចំណែក **តារា** ឃើញមនុស្សមកចោមរោមមើលខ្លួនដូច្នោះ អ្នកនឹកឆ្ងល់ណាស់ បុរសធ្វើឡឹងឡង់តែអ្នកនៅតែឈានជើងអ្នកដើរត១ទៅមុខជាលំដាប់។ ហើយអ្នកតែងតែក្រឡេកមើលឆ្វេង ស្តាំក្រែងបានប្រទះឃើញគូ

កំសត់របស់អ្នក អ្នកនឹកទន្ទិញពាក្យក្នុងចិត្តថា : " **ផាលា** អូនអើយ ! បងមករកនាងហើយ ទោសកំហុសរបស់បងទាំងអម្បាលម៉ាន សូមពៅលើកចោលទៅណាអូនណ៎ា ពីថ្ងៃនេះតទៅមុខ បងលែងធ្វើពុតអាក្រក់ទៀតហើយ "។ **តារា** ចេះតែងាករកមើលសង្សារក្នុងចំណោមមនុស្សទាំងនោះ តែខណៈហ្នឹងអ្នកឥតបានឃើញនាង **ផាលា** សោះ។ អ្នកក៏ចេះតែដើរត១ទៅទៀតទៅជួប **ពូឡាច** ទើបអ្នកបញ្ចេញវាចារសួរទៅថា : " មា ! មានឃើញ **ផាលា** មកដល់ហើយឬនៅ ? "។ **ពូឡាច** ធ្វើមុខស្ងួត ហើយក៏ដើរនាំផ្លូវ **តារា** ទៅតែគាត់ឥតចេញវាចាមួយមាត់សោះ គាត់គ្រាន់តែដើរពីមុខ តារា ទៅ ... ហាក់ដូចជា គាត់បង្ខំដល់បុរសនេះឱ្យដើរទៅកាន់ខ្ទមនាង **ផាលា** យ៉ាងរហ័សតាមគាត់។

ដល់បានទៅដល់ខ្ទមស្រីកំព្រានោះហើយ **ពូឡាច** លើកដៃចង្អុលទៅក្នុងខ្ទមនោះ បីដូចជាគាត់ចង្អុលប្រាប់មហន្តរឿងអ្វីមួយដែលមាននៅក្នុងខ្ទមនោះ។

**តារា** ដើរចូលទៅក្នុងខ្ទមរៀបនឹងបញ្ចេញសំឡេងហៅនាង **ផាលា** ស្រាប់តែបុរសក្រឡេកទៅឃើញរូបរាងជាមនុស្សម្នាក់ទទួលភួយស្តុងជិតមុខ ហើយធំអាសោចិភាយ១មក... ។

បុរសភ្ញាក់ខ្លួនព្រឺតភ័យញ័រចំប្រក់ក្នុងទ្រូង ហើយចូលទៅជិតទាញភួយបើកមើលរូបបុគ្គលនោះ ស្រាប់តែឃើញ ... មុខនាង **ផាលា** សង្សារថ្មើមប្រមាត់របស់ខ្លួនសោះ។ អ្នកស្រែកយំរៀបរាប់ : " ឱ ! កម្មអ្វី ! **ផាលា** ! **ផាលា** ! មិនគួរអូនស្លាប់សោះ បងមកដល់ហើយអូន ស្តាយស្តាយបងមកមិនទាន់ ... "។

សំឡេងរបស់ **ពូឡាច** ដែលគាត់ទៅឈរក្រោយខ្នង **តារា** ឮឡើងថា: " នាងទៅលោតទម្លាក់ខ្លួនពីលើភ្នំបាក់ខែងតាំងពីល្ងាចមិញម្ល៉េះ ខ្ញុំខំប្រឹងតែដើររកទាល់ដល់ព្រឹកមិញនេះ ទើបបានដឹងដំណឹងរួចខ្ញុំទៅលើកនាងយកមកដាក់ក្នុងខ្ទមនេះ "។

**តារា** ឈ្ងោកមើលឃើញក្បាលសង្សាររបស់អ្នកបែកខ្ទេចអស់ ១ ចំហៀង ហើយអ្នកក៏ឱបខ្មោចនោះទ្រហោយំយ៉ាងខ្លាំង។ អ្នកងើបមើលទៅក្បៀនជញ្ជាំងក្បែរក្បាលនាង **ផាលា** ឃើញថូកែវមួយ ដែលមានដាក់ឆ្អឹងយាយចាន់ អ្នកក៏រំងិរិតក្តុកក្តួលក្នុងទ្រូងឡើងអ្នកនឹកថា : " ធាតុនេះគឺធាតុយាយចាន់ ឱ ខ្លួនអញមិនគ្រាន់តែធ្វើឱ្យគេកើតទុក្ខរហូតឱ្យគេដល់ទៅស្លាប់អស់ពីរនាក់ដោយសារតែគំនិតខិលខូច អូនអើយម្តេចនាងទៅលោតសម្លាប់ខ្លួនឯងឱ្យស្លាប់ចោលបង ឱ្យបងនៅរងទុក្ខចិត្តនាងឥតក៏មុតម្ល៉េះ នាងហ៊ានទៅលោតទំលាក់ខ្លួន

ពីលើកំពូលភ្នំ កម្មអ្វីក៏ក្រាស់ម្ល៉េះមកប្រទាញចិត្តរបស់បងឱ្យស្អប់នាង កាលដែលនាងទៅរកបងនៅឯភ្នំពេញ ។

យប់នោះ **តារា** និង **ពូឡាច** នៅនិយាយគ្នារអ៊ូៗទាល់តែដល់យប់ជ្រៅ ។ ក្លិនអាសោចិរបស់នាង **ផាលា** ក៏កាន់ត្រធុំភាយៗញាប់ៗឡើង ទោះតែធុំអាសោចិយ៉ាងណាក៏ដោយ **តារា** ក៏នៅតែធ្វើព្រងើយ **តារា** ហិតក្លិនសំអុយបុគ្គលនេះ ក៏ហាក់ដូចជាហិតក្លិនផ្កាយ៉ាងក្រអូបទៅវិញ **តារា** ចេះតែអង្គុយសញ្ជប់សញ្ជឹងសំឡឹងដល់រូបបុគ្គល **តារា** មានសេចក្ដីអាណោចអាធ័មយ៉ាងពន់ពេកយប់កាន់តែយន់ណាស់ទៅហើយ **តារា** ស្ដាប់ឮសូរសំរែកខ្លែងស្រាក មកស្រែកក្អាកៗនៅលើចុងដើមស្វាយដែលដុះនៅមុខខ្ទម ។ ឯវាយោក៏បក់មករ៉ូៗធ្វើឱ្យស្លឹកត្នោតនៃខ្ទមនោះកំរើកញាប់ញ័រ ។ ដើមចេកជាច្រើនគុម្ព នឹងដើមផ្កាជាច្រើនដើមដែលចុះនៅខាងក្រោយខ្ទមនោះខំបក់បោកសន្លឹកឮសូប្រាវៗ ហាក់បីដូចជាចេញសំឡេងសោកសៅស្រណោះដល់ម្ចាស់ស្រី ដែលនាងធ្លាប់តែយកទឹកទៅចាក់ចិញ្ចឹមឱ្យរស់ ឥឡូវនាងស្លាប់ទៅហើយ តើបានអ្នកណាស្រោចទឹកឱ្យទៀតនេះហើយហេតុតែពីសេចក្ដីស្នេហាមិនបានប្រកបដូចចិត្តក៏អាចហ៊ានសម្លាប់ជីវិតខ្លួនឯងយ៉ាងដាច់ចិត្ត ... ។

នាកាលកន្លងពីរាត្រីផុតទៅ ព្រះសូរិយាក៏រះឡើងតែឃើញនៅទៀបមាត់ព្រៃនៅឡើយ ចាំងរស្មីពណ៌ក្រហមឆ្អិនឆ្អៅប្រាលអស់មួយចំហៀងមេឃ ។ សំបុកសត្វចាបដែលនៅដេរដាសលើដើមក្រសាំងក្បែរខ្ទមនាង **ផាលា** ឮសូរនិយាយគ្នាចីកចាចៗ ហើយក៏ហើរចាកចេញអំពីសំបុកទាំងគូៗ ខ្លះនាំកូនទាំងហ្វូងៗ ដើម្បីទៅស្វែងរកចំណីអាហារ ។ សត្វមាន់ក៏បន្លឺយនូវសំរែក ។ សត្វកុកទទះស្លាបចុះមកឆ្នក់ត្រីក្នុងវាលស្រែ ឬថ្លុកត្រពាំងបឹងបួ ។ សត្វទានាំគ្នាហែលលេងក្នុងទឹកស្ទឹងសៀមរាប ។ ហ្វូងសត្វពពេចហើរកាត់កំពូលប្រាសាទ ។ សត្វក្អែកស្រែកយំរ៉កៗលើដើមអង្កាដី ។



ពេលនេះហើយដែលគេឃើញ **តារា** ត្រកងខ្មោចនាង **ផាលា** ដែលរឹងស្តូកស្តឹង ចេញចាកអំពីភូមិនាគឆ្លងថ្មល់ទៅសួស្តានអង្គរវត្ត រួចដើរបត់ទៅរកវត្តដែលស្ថិតនៅខាងជើងប្រាសាទអង្គរ ។

**តារា** យកបុគ្គលនេះទៅដាក់លើគំនរអុសដែលរៀបទុកយ៉ាងខ្ពស់។ មួយសន្ទុះមកភ្លើងអុសដ៏ក្រហមឆ្អិនឆ្អៅក៏ឆេះឆាបបុគ្គល



នាង **ផាលា** ហើយបង្ហុយផ្សែងខ្មៅហុយយ៉ាងត្រលោមទៅលើអាកាស។ ចំនួន ពីរបីម៉ោងក្រោយមករូបរាងនាង **ផាលា** ក៏រលាយបាត់ៗ នៅសល់តែឆ្អឹង ស ប្រផេះយ៉ាងផុយតូចៗប៉ុនៗកូនដៃលាយនឹងធ្យូងខ្មៅ។

គេឃើញ **តារា** វាចធ្យូងអុសរើសឆ្អឹងនាង **ផាលា** បានមួយកញ្ចប់ មុខ **តារា** ស្រពោនឡើងខ្មៅ បន្តិចមកបុរសបង្ហូរទឹកភ្នែក ហើយពោលល្ហឹមៗឡើងថា : " ឱ ! **ផាលា** ! **ផាលា** ! អូនអើយ ! នាងមិនគួរស្លាប់ទៅចោលបងសោះអូ ! រូបអញអឺយ ! ថ្ងៃណាក៏គង់តែសូន្យដូចជារូប **ផាលា** ដែរ អញមិនអាចនឹងចៀសសេចក្តីស្លាប់នេះផុតទេ ! គួរភ័យគួរសង្វេករូបណាស់ ដើម្បីលាផុតអំពីទុក្ខគ្រប់ប្រការ លាផុតអំពើលាមកទាំងអម្បាលម៉ានមានតែអញត្រូវទៅបួសប្រយោជន៍ឱ្យឃើញជាក់ស្តែង សេចក្តីដ៏បរិសុទ្ធសុចរិតរបស់អញតបទៅលើរូបនាង **ផាលា** និង យាយចាន់វិញនៃ ! ចិត្ត គំនិតខ្ញុំអើយ ! បើបានជាប្រព្រឹត្តខុសម្តងនេះទៅហើយ ខ្ញុំមិនត្រូវធ្វើឱ្យខុសតទៅអនាគតទៀតទេ " ។ ផាលា អូនអើយ ! ចាប់តាំងពីថ្ងៃនេះទៅ បងលះបង់អំពើទុច្ចរិតរបស់បងហើយបងខំស្វែង

រកធមិប្រតិស្ឋអធិដ្ឋានបញ្ជូនកុសលទៅឱ្យដល់អូន ដើម្បីជាតិក្រោយបងសុំប្រាថ្នាឱ្យបានជួបនឹងអូនវិញ សូមកុំឱ្យវេទនា អកុសលដូចជាតិនេះ។

ប៉ុន្មានថ្ងៃក្រោយមក គេបានដឹងដំណឹងថា : " **តារា** ទៅបួសធ្វើជាភិក្ខុសង្ឃមួយអង្គ ហើយព្រះសង្ឃនេះតែងតែចូលចិត្តទៅគង់លើកំពូលភ្នំ ឬក្នុងព្រៃណាជ្រៅៗដែលជាស្ថានស្ងាត់លំនៅរបស់ពពួកសត្វ ភិក្ខុអង្គនេះតែងតែចូលចិត្តយកសត្វម្រឹគីម្រឹគាធ្វើជាញាតិ "។

**-ចប់_**

ជិតចេញផ្សាយទៀតហើយ !!
រឿង "**នៅក្នុងលោកនេះបើគ្មានបង**" របស់អ្នកនិពន្ធ
**ហាក់ នៃហុក** ជាប្រលោមលោកមនោសញ្ចេតនា
ដែលកើតឡើង នាអំឡុងទសវត្សទ៦០ ពីបណ្ណាគារ
"**អង្គរធំ**" នេះដដែល ធានាថាល្អពិរោះរណ្ដំ
ក្នុងអារម្មណ៍យុវវ័យគ្រប់ៗរូប !!!

សេចក្ដីជម្រាប

ក្រោយពីការបោះពុម្ពផ្សាយឡើងវិញ នូវរឿងមួយចំនួនកន្លងមកនេះ បណ្ណាគារយើងខ្ញុំ បានទទួលមតិរិះគន់កែលំអយ៉ាងផុលផុសពីសំណាក់លោក-អ្នកដែលស្រឡាញ់វិស័យនេះ ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិភាគទានដ៏ថ្លៃថ្លាទាំងអស់នេះ ហើយយើងខ្ញុំនឹងខិតខំកែលំអឱ្យអស់ពីលទ្ធភាព ដើម្បីឈានទៅរកសុក្រិតភាពជាលំដាប់ ។ យើងខ្ញុំសូមប្រសិទ្ធពរជ័យបវរដល់លោក-អ្នក ហើយសូមឱ្យលោក-អ្នក បានភពប្រសព្វតែនឹងសេចក្ដីសុខក្សេមក្សាន្ត កុំបីឃ្លៀងឃ្លាតឡើយ ។

អង្គរធំ